ឆ្ពោះទៅរកការទទួលបានដី និងធនធានធម្មជាតិប្រកបដោយសមធម៌ និង សុវត្ថិភាពសម្រាប់គ្រួសារកសិករនៅក្នុងតំបន់មេគង្គ

## ឯកសារសម្រាប់ការរៀនសូត្រ

inclusive development international

MRLG MEKONG REGION LAND GOVERNANCE

អង្គការ សមធម៌កម្ពុជា equitable cambodia

ខែកក្កដា ឆ្នាំ២០១៦

# អភិក្រមប្រកបដោយភាពច្នៃប្រឌិតថ្មី ចំពោះការដោះស្រាយវិវាទដីធ្លី

## មេរៀនបទពិសោធន៍ពីដំណើរការសម្រុះសម្រួលវិវាទ រវាងក្រុមហ៊ុន HAGL និងសហគមន៍ជនជាតិដើមភាគតិច ក្នុងខេត្តរតនៈគិរី ព្រះរាជាណាចក្រកម្ពុជា







*អង្គការ សមធម៌កម្ពុជា និងអង្គការ Inclusive Development International*

*គម្រោងអភិបាលកិច្ចដីធ្លីតំបន់មេគង្គ*

# កំណត់សម្គាល់សម្រាប់ការរៀនសូត្រ

និពន្ធដោយ Courtney WORK

ដោយមានកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការដឹកនាំគម្រោង ដែលរួមមានសមាសភាពដូចជា ៖ CASTELLANET, David PRED, Natalie BUGALSKI, អ៊ាង វុទ្ធី, Mark GRIMSDITCH, and Jean-Christophe DIEPART។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖

**David PRED** នៃអង្គការ Inclusive Development International: <david@inclusivedevelopment.net>

**អៀង វុទ្ធី** អង្គការ សមធម៌កម្ពុជា : <vuthy@equitablecambodia.org>

**ដំ ចន្ធី** សមាគមខ្មែរលើ : <haratanakiri@gmail.com>

**ង៉ាច សាមីន** អង្គការយុវជនជនជាតិដើមភាគតិចកម្ពុជា : <ngsamin@gmail.com>

**មឿន វុទ្ធី** បណ្ដាញសមាជិកសកម្មរបស់ជនជាតិដើមភាគតិច : <vuthymoeun.ip@gmail.com>

បកប្រែជាភាសាខ្មែរដោយ លោក **សុខ គន្ធី**

ពិនិត្យនិងផ្ទៀងផ្ទាត់ភាសាខ្មែរឡើងវិញដោយ លោក **ប៉ុច សោភ័ណ**

ការផ្ដល់យោបល់សម្រាប់ការដកស្រង់ខ្លឹមសារពីអត្ថបទនេះ ៖

Work, C. (2016). *Innovative approach to land conflict transformation. Lessons learned from the HAGL/ indigenous communities' mediation process in Ratanakiri, Cambodia.* MRLG Capitalization Note Series #1. Vientiane & Phnom Penh: Mekong Region Land Governance, Equitable Cambodia and Inclusive Development International.

ស្នាដៃនេះបានទទួលការអនុញ្ញាតក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-NonCommercial-ShareAlike 4.0 International License

# តារាងមាតិកា


**សេចក្ដីសង្ខេបរួម** ii

**ព័ត៌មានអំពីសាវតា** ១

**សេចក្ដីអធិប្បាយអំពីដំណើរការដោះស្រាយវិវាទ** ៣

**លទ្ធផល/ធាតុចេញសំខាន់ៗ** ១០

ការកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន ១០

*វគ្គបណ្ដុះបណ្ដាលដែលមានការចូលរួមពីសហគមន៍និងតំណាងអង្គការមិនមែនរដ្ឋាភិបាល* ១០

*សកម្មភាពនៅថ្នាក់ភូមិ* ១១

កិច្ចប្រជុំសម្រុះសម្រួលដោះស្រាយវិវាទ និងការប្ដេជ្ញាចិត្តរបស់ភាគីក្រុមហ៊ុន ១២

ឧបករណ៍ និងធនធានដែលបានផលិត និងប្រើប្រាស់ ១៤

ការផ្សព្វផ្សាយ ១៥

ការកំណត់ករណីគំរូ សម្រាប់វិនិយោគិនអន្តរជាតិ ១៦

**មេរៀនបទពិសោធន៍ដែលបានរៀនសូត្រ** ១៧

ទំនាក់ទំនងនៃវិសមភាពអំណាច ១៧

ការប្ដេជ្ញាចិត្តរបស់សហគមន៍ ១៨

តម្រូវការពេលវេលា និងភាពមោះមុត ១៩

ការធ្វើផែនទីសហគមន៍ ១៩

ការសម្របសម្រួល និងការប្រាស្រ័យទាក់ទង ដោយអង្គការមិនមែនរដ្ឋាភិបាល ២០

ការតាមដានស្វែងរកប្រភពថវិកា ២០

ការចរចារជាមួយអាជ្ញាធរថ្នាក់មូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិ ២១

**លក្ខខណ្ឌសម្រាប់ការចម្លងយកគំរូនេះ** ២២

**សេចក្ដីសន្និដ្ឋាន** ២៣

**ឯកសារយោង និងការផ្ដល់មតិយោបល់អំពីឯកសារដែលគួរអាន** ២៤

**ឧបសម្ព័ន្ធ** ២៥

# សេចក្ដីសង្ខេបរួម

## ព័ត៌មានអំពីសាវតា

សហគមន៍នៅក្នុងប្រទេសកម្ពុជា កំពុងបន្តរងគ្រោះពីភាពក្រីក្រនិងការផ្លាស់ប្ដូរទីលំនៅដោយសារលទ្ធកម្មដីធ្លីទ្រង់ទ្រាយធំ ដែលត្រូវបានរៀបចំឡើង ក្នុងគោលបំណងដើម្បីបង្កើនផលិតកម្មកសិកម្ម និងកាត់បន្ថយភាពក្រីក្រ។ គិតត្រឹមចុង ឆ្នាំ២០១៤ ប្រទេសកម្ពុជាបានផ្ដល់សម្បទានដីសេដ្ឋកិច្ចប្រមាណ ៤៩០សម្បទាន ដែលក្នុងនោះ រាប់បញ្ចូលសម្បទានសម្រាប់រុករករ៉ែផងដែរ ដោយមានផ្ទៃដីសរុបចំនួន ៤,៥លានហិកតា ដែលស្មើនឹងប្រមាណ២៥ភាគរយ នៃផ្ទៃដីសរុប (Messerli et al., 2015)។ ដីទាំងនេះភាគច្រើនត្រូវបានផ្លាស់ប្ដូរពីព្រៃក្រាស់ៗទៅជាប្រភេទដីចម្ការនានា ដោយសារសម្បទានដីសេដ្ឋកិច្ច (ELC)។ ក្នុងឆ្នាំ២០០៩ ការប្រែប្រួលយ៉ាងគំហុកទៅលើការប្រើប្រាស់ដីទាំងនេះ បានចាប់ផ្ដើមបង្កឱ្យមានផលប៉ះពាល់ទៅលើសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនៈគិរី នៅភាគឦសានប្រទេសកម្ពុជា ។ ការស៊ើបអង្កេតមួយបានធ្វើឡើងដោយ Global Witness (GW) ទៅលើផលិតកម្មកៅស៊ូក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ (ឆ្នាំ២០១២) បានបង្ហាញឱ្យដឹងថាចម្ការកៅស៊ូជាច្រើនក្នុងខេត្តរតនៈគិរី គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនឯកជនធំជាងគេបំផុតមួយ របស់ប្រទេសវៀតណាម ដែលមានឈ្មោះថាក្រុមហ៊ុនហុងអាញ់យាឡាយ (HAGL)។ ក្រុមហ៊ុននេះ មានទំនាក់ទំនងជិតស្និទ្ធជាមួយឥស្សរជននយោបាយ និងធុរកិច្ចក្នុងប្រទេសកម្ពុជា ដែលបានអនុញ្ញាតឱ្យពួកគេរំលោភបំពានទៅលើទំនៀមទម្លាប់ប្រពៃណីក្នុងមូលដ្ឋាន ព្រមជាមួយនឹងការទទួលបាននូវនិទណ្ឌភាព និងលាក់បាំងការធ្វើជំនួញរបស់ ពួកគេដោយសម្ងាត់។ នៅពេលចាប់ផ្ដើមកិច្ចព្រមព្រៀងសម្បទានរបស់ពួកគេពីដំបូង ក្រុមហ៊ុន HAGL បាន ទទួលមូលនិធិគាំទ្រពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា ធនាគារ Deutsche Bank, Credit Swiss និង សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាសាខាផ្នែកវិស័យឯកជនរបស់ធនាគារពិភពលោក។

ចម្ការកៅស៊ូរបស់ក្រុមហ៊ុន HAGL ក្នុងខេត្តរតនៈគិរី បានបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសហគមន៍ជនជាតិដើមភាគតិចចំនួនយ៉ាងហោចណាស់ ១៤។ ពួកគេបានបាត់បង់ដីព្រៃ ស្រែចម្ការ សហគមន៍ ដីកប់ខ្មោច ដីព្រៃអារក្ស កន្លែងនេសាទ និងដីបម្រុងទុកសម្រាប់មនុស្សជំនាន់ក្រោយ។ GW បានសំណូមពរ ឱ្យអង្គការ Inclusive Development International (IDI) ធ្វើការប៉ាន់ប្រមាណថាតើមានការរំលោភបំពានទៅលើគោលនយោបាយរបស់ IFC ស្ដីពីអន្តរការីហិរញ្ញវត្ថុដែរឬទេ និងថាតើពាក្យបណ្ដឹងបានដាក់ទៅ ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (CAO) ដែលជាយន្តការគណនេយ្យភាពរបស់ IFC មានលក្ខខណ្ឌសមស្របដែរឬទេ។ នៅពេលនោះ IDI បានទាក់ទងអង្គការមិនមែនរដ្ឋាភិបាលជាតិមួយ ដែលមានឈ្មោះថាអង្គការសមធម៌កម្ពុជា (EC) ដើម្បីឱ្យធ្វើការពិនិត្យថា តើសហគមន៍រងផលប៉ះពាល់មានបំណងស្វែងរកដំណោះស្រាយពីក្រុមហ៊ុន HAGL ដែរឬទេ។ ក្រោយពេលធ្វើការតស៊ូមតិ និងការចរចារអស់រយៈពេលជាង ២៧ ខែកន្លងមក នៅពេលកំពុងសរសេររបាយការណ៍នេះ ដំណើរការសម្រុះសម្រួលដោះស្រាយវិវាទ មិនទាន់បញ្ចប់នៅឡើយទេ។ បើទោះជាដូច្នេះក្ដី ពួកគេសម្រេចបាននូវវឌ្ឍនភាពដ៏វិសេសវិសាលមួយ។ តំណាងរបស់ក្រុមហ៊ុន HAGL បានបញ្ជាក់អំពីការប្ដេជ្ញាចិត្តរបស់ក្រុមហ៊ុន ថានឹង មិនធ្វើការឈូសឆាយ ឬ អភិវឌ្ឍន៍បន្ថែមទៀតទៅលើសម្បទានដីសេដ្ឋកិច្ចរបស់ខ្លួន និងប្រគល់ជូនសហគមន៍វិញនូវដី និងព្រៃសេសសល់ដែលមិនទាន់បានអភិវឌ្ឍន៍។ សម្បទានដីសេដ្ឋកិច្ច

របស់ក្រុមហ៊ុនហ៊ោងអានអូរយ៉ាឡាវ ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន HAGL ត្រូវបានអាជ្ញាធរខេត្ត កាត់បន្ថយចំនួន ១៣.៧២០ ហិកតា (ពី១៦.៨៤៩ ហិកតា មកត្រឹម ៣.១២៩ ហិកតា)។

សេចក្តីថ្លែងការណ៍រួម អាចរកបាន តាមរយៈអាសយដ្ឋានភ្ជាប់ខាងក្រោម ៖

[http://www.inclusivedevelopment.net/wp-content/uploads/2015/09/Joint-Statement-Villages-Group-2-16-Sept-2015-EngKh4clean-SS-1.pdf](http://www.inclusivedevelopment.net/wp-content/uploads/2015/09/Joint-Statement-Villages-Group-2-16-Sept-2015-EngKh4clean-SS-1.pdf)

[http://www.inclusivedevelopment.net/wp-content/uploads/2015/09/Joint-Statement-Villages-Group-3-19-Sept-2015-Eng.pdf](http://www.inclusivedevelopment.net/wp-content/uploads/2015/09/Joint-Statement-Villages-Group-3-19-Sept-2015-Eng.pdf)

## មេរៀន និងបញ្ហាប្រឈមនានា

⇒ ចំណុចសំខាន់នៃការផ្តួចផ្តើមនេះ គឺជាការសម្រុះសម្រួលដោះស្រាយវិវាទ និងការចរចារអំពីទំនាក់ទំនងនៃវិសមភាពអំណាច។ វាមានសារៈសំខាន់ដែលត្រូវមានអ្នកសម្រុះសម្រួលដោះស្រាយវិវាទមួយរូប ប្រកបដោយគុណវុឌ្ឍិការងារខ្ពស់ ដែលយល់អំពីអតុល្យភាពអំណាច ហើយវាក៏មានសារៈសំខាន់ផងដែរ ចំពោះអង្គការដែលគាំទ្រ ត្រូវចាក់ឫសគល់ និងចំណាយពេលវេលាមួយចំនួននៅ ក្នុងសហគមន៍ដែលរងផលប៉ះពាល់ ដើម្បីឱ្យយល់អំពីការយល់ឃើញរបស់សហគមន៍ទាំងនោះ។

⇒ នៅក្នុងដំណើរការបែបនេះ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើការងារជាមួយមេដឹកនាំប្រពៃណី។ ប្រសិនបើគេត្រូវការឱ្យមានយុវជនវ័យក្មេងដើម្បីសម្របសម្រួលការប្រាស្រ័យទាក់ទង ជាមួយពិភពខាងក្រៅ ពួកគេគប្បីស្ថិតនៅក្រោមសិទ្ធិអំណាច (និងរាយការណ៍ជូន) ចាស់ព្រឹទ្ធាចារ្យ។

⇒ នេះគឺជាការផ្តួចផ្តើមមួយដ៏ស្មុគស្មាញដែលមានអ្នកពាក់ព័ន្ធច្រើន តម្រូវឲ្យមានការប្រមូលទិន្នន័យបច្ចេកទេសលម្អិត និងទាមទារឱ្យមានការចរចារដោយប្រុងប្រយ័ត្ន ដែលកើតឡើងនៅក្នុងអំឡុងពេលដែលមានសកម្មភាពខ្លាំងក្លា និងមានការកាត់សង្វាក់ ក្នុងការរង់ចាំអស់រយៈជាច្រើនខែ។ ការផ្តល់កិច្ចគាំទ្រជូនសហគមន៍ រួមមានកិច្ចខិតខំបណ្តុះបណ្តាលយ៉ាងល្អិតល្អន់ម្តងហើយម្តងទៀត ដែលចាំបាច់ត្រូវធ្វើការចងក្រងឯកសារធនធាន និងធ្វើផែនទី ដែលជាចំណុចបង្កឱ្យមានការលំបាកចំពោះបញ្ហាបុគ្គលិក និងថវិការបស់អង្គការមិនមែនរដ្ឋាភិបាល។

⇒ បើទោះបីជាវាមានសារៈសំខាន់ក្នុងការមានអង្គការនានាសហការនៅកម្រិតអន្តរជាតិ កម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ក៏ដោយ ប៉ុន្តែចំនួននៃអង្គការទាំងនេះ គប្បីមានកម្រិត។ បន្ថែមពីនេះទៀត ត្រូវធានាឱ្យបាននូវការសម្របសម្រួលដ៏រឹងមាំនៅកម្រិតមូលដ្ឋាន តាមរយៈវត្តមានរបស់អង្គការជាតិនាំមុខ។

⇒ ប្រសិនបើគ្មានសម្ពាធហិរញ្ញវត្ថុ ដែលបានបង្កើតឡើងដោយការទាក់ទងផ្ទាល់ជាមួយអ្នកផ្តល់កិច្ចគាំទ្រ

ផ្នែកហិរញ្ញវត្ថុទេនោះ ដំណើរការដោះស្រាយវិវាទប្រាកដជានឹងគ្មានការវិវឌ្ឍន៍ទៅមុខឡើយ។ យ៉ាងណាមិញ នេះគឺជាដំណើរការមួយដែលត្រូវចំណាយថវិកា និងពេលវេលាច្រើន។

⇒ ការចរចារជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ខេត្ត មានសារៈសំខាន់ខ្លាំងណាស់នៅពេលចាប់ផ្ដើមដំណើរការសម្រុះសម្រួលដោះស្រាយវិវាទ។ សម្រាប់ជំហានដំបូងនៃការគៀងគរភូមិរងផលប៉ះពាល់ ការប្រាស្រ័យទាក់ទងជាមួយមន្ត្រីថ្នាក់មូលដ្ឋាន អាចធ្វើឱ្យរីករាលដាលនូវភាពតានតឹង ឬ មិនធ្វើឱ្យរីករាលដាលនូវភាពតានតឹង។

## លក្ខខណ្ឌសម្រាប់ការចម្លងយកគំរូនេះ ៖

⇒ ក្រុមហ៊ុនត្រូវតែមានកម្រិតងាយរងគ្រោះគ្រប់គ្រាន់ចំពោះវិនិយោគិនរបស់ពួកគេ។

- ចំពោះក្រុមហ៊ុនដែលមានរដ្ឋគាំទ្រពីក្រោយ ឬមានទំនាក់ទំនងស៊ីជម្រៅជាមួយរដ្ឋាភិបាលជាតិរបស់ពួកគេ វាមានការលំបាកខ្លាំង ក្នុងការដាក់សម្ពាធទៅលើក្រុមហ៊ុនទាំងនោះ។
- យ៉ាងហោចណាស់ប្រសិនបើអាចរកឃើញចំណុចដាក់សម្ពាធដ៏ខ្លាំងមួយ ទើបជាយុទ្ធសាស្ត្រ មានតម្លៃក្នុងការបន្តអនុវត្ត។ ប៉ុន្តែបើទោះជាដូច្នេះក្ដី ដើម្បីឱ្យមានប្រសិទ្ធភាពខ្លាំងបំផុតនោះ ត្រូវការឱ្យមានចំណុចដាក់សម្ពាធច្រើន។
- យុទ្ធសាស្ត្រនេះមិនសូវមានប្រសិទ្ធភាពឡើយជាមួយវិនិយោគិនឯកជនតូចៗ។

⇒ វិនិយោគិន និងម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ត្រូវមានឆន្ទៈក្នុងការគាំទ្រដល់យុទ្ធនាការតស៊ូមតិ និងដាក់សម្ពាធទៅលើក្រុមហ៊ុន។

⇒ ចាំបាច់ត្រូវការឱ្យមាន អង្គការដែលមានការប្រាស្រ័យទាក់ទង និងឥទ្ធិពលផ្សេងៗគ្នា។ អន្តរាគមន៍នេះទាមទារឱ្យមានអង្គការដែលមានជំនាញឯកទេសកម្រិតអន្តរជាតិ កម្រិតថ្នាក់ជាតិ និងកម្រិតមូលដ្ឋាន។

⇒ អង្គការដែលផ្ដួចផ្ដើមដំណើរការនេះ ត្រូវមានធនធានថវិកា និងធនធានមនុស្សគ្រប់គ្រាន់ ដើម្បីចូលក្នុងដំណើរការនេះ។

- អង្គការសមធម៌កម្ពុជាតែឯងបានចំណាយថវិកាជាង ១០០.០០០ ដុល្លារសហរដ្ឋអាមេរិក ទៅហើយ ក្នុងរយៈពេល ២៧ខែនេះ ហើយនៅសល់ការងារជាច្រើនទៀតដែលត្រូវធ្វើ
- ត្រូវធ្វើសិក្ខាសាលា និងការបណ្ដុះបណ្ដាលមួយចំនួនឱ្យបានល្អិតល្អន់ជាមួយសហគមន៍ និងដៃគូនៅថ្នាក់មូលដ្ឋាន

- អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន អាចត្រូវការការកសាងសមត្ថភាពយ៉ាងសំខាន់នៅគ្រប់ដំណាក់កាលទាំងអស់
- អង្គការត្រូវមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ភាពបត់បែនប្រភេទនេះ។

ｏ ត្រូវការឱ្យមានជំនួយលើការពិនិត្យតាមដាន និងពេលវេលារបស់បុគ្គលិក នៅក្នុងចន្លោះពេលវេលាមួយដែលមិនទៀងទាត់។

⇒ សហគមន៍ត្រូវធ្វើការវិនិយោគនៅក្នុងដំណើរការនេះ មានសាមគ្គីភាពរឹងមាំ និងទទួលបានឧបករណ៍ដែលពួកគេត្រូវការដើម្បីបង្ហាញអំពីសេចក្តីត្រូវការរបស់ពួកគេ ឱ្យក្រុមហ៊ុនបានដឹង។ ប្រសិនបើគ្មានសហគមន៍ទេនោះ វាគឺជាបញ្ហាមួយរបស់អង្គការមិនមែនរដ្ឋាភិបាល និងពុំមានទម្ងន់អ្វីឡើយ។

⇒ ការវាយតម្លៃហានិភ័យផ្នែកសុវត្ថិភាពនៅក្នុងគ្រប់ស្ថានភាពទាំងអស់ ដើម្បីកំណត់ថាតើយុទ្ធសាស្ត្រនេះមានតម្លៃក្នុងការបន្តអនុវត្តនៅក្នុងករណីមួយដែរឬទេ។

# ព័ត៌មានអំពីសាវតា

សហគមន៍នៅក្នុងប្រទេសកម្ពុជា កំពុងបន្ទរងគ្រោះពីភាពក្រីក្រ និងការផ្លាស់ប្តូរទីលំនៅដោយសារលទ្ធកម្មដីធ្លីទ្រង់ទ្រាយធំ ដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតកម្មកសិកម្ម និងកាត់បន្ថយភាពក្រីក្រ។ គិតត្រឹមចុងឆ្នាំ២០១៤ ប្រទេសកម្ពុជាបានផ្តល់សម្បទានដីសេដ្ឋកិច្ចប្រមាណ ៤៩០ ដែលក្នុងនោះ រាប់បញ្ចូលសម្បទានសម្រាប់រុករករ៉ែផងដែរ ដោយមានផ្ទៃដីសរុបចំនួន ៤,៥លានហិកតា ដែលស្មើនឹងប្រមាណ ២៥% នៃផ្ទៃដី សរុប (Messerli et al., 2015, 141)។ ដីទាំងនេះភាគច្រើនត្រូវបានផ្លាស់ប្តូរពីព្រៃក្រាស់ៗទៅជាប្រភេទដីចម្ការនានាដោយសារសម្បទានដីសេដ្ឋកិច្ច (ELC)។ ក្នុងឆ្នាំ២០០៩ ការប្រែប្រួលយ៉ាងគំហុកទៅលើការប្រើប្រាស់ដីទាំងនេះបានចាប់ផ្តើមបង្កឱ្យមានផលប៉ះពាល់ទៅលើសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនៈគិរីនៅភាគឦសាន ប្រទេសកម្ពុជា ។ ការស៊ើបអង្កេតមួយបានធ្វើឡើងដោយ Global Witness (GW) ទៅលើផលិតកម្មកៅស៊ូក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ (ឆ្នាំ២០១២) បានបង្ហាញឱ្យដឹងថា ចម្ការកៅស៊ូជាច្រើន ក្នុងខេត្តរនតៈគិរី គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនឯកជនធំជាងគេ បំផុតមួយរបស់ប្រទេសវៀតណាម ដែលមានឈ្មោះថាក្រុមហ៊ុនហុងអាញ់យាឡាយ (HAGL)។ ក្រុមហ៊ុននេះ មានទំនាក់ទំនងជិតស្និទ្ធជាមួយឥស្សរជននយោបាយ និងធុរកិច្ចក្នុងប្រទេសកម្ពុជា ដែលបានអនុញ្ញាតឱ្យពួកគេធ្វើជំនួញរបស់ពួកគេដោយសម្ងាត់ និងប្រើប្រាស់ផ្លូវកាត់នៅក្នុងដំណើរការប្រក្រតីដើម្បីទទួលបានសម្បទានរបស់ពួកគេ។ នៅពេលចាប់ផ្តើមកិច្ចព្រមព្រៀងសម្បទានរបស់ពួកគេពីដំបូង ក្រុមហ៊ុន HAGL បានទទួលកិច្ចគាំទ្រហិរញ្ញវត្ថុពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាធនាគារ Deutsche Bank, Credit Swiss និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) ដែលជាសាខាផ្នែកវិស័យឯកជនរបស់ធនាគារពិភពលោក។

### ការតាមដានស្វែងរកប្រភពថវិកា

IFC បានផ្តល់ហិរញ្ញប្បទានជូនដល់ក្រុមហ៊ុន HAGL តាមរយៈក្រុមហ៊ុន Dragon Capital Group Ltd (Dragon Capital) ដែលជាក្រុមវិនិយោគមួយមានមូលដ្ឋានក្នុងប្រទេសវៀតណាម និងមានឯកទេស ផ្នែកទីផ្សារហិញ្ញវត្ថុកំពុងរីកចម្រើន។ IFC ដែល ជាម្ចាស់ភាគហ៊ុនមួយនៅក្នុងក្រុមហ៊ុន Dragon Capital តាំងពីឆ្នាំ២០០២ បានវិនិយោគ ដោយផ្ទាល់ផងដែរនៅក្នុង Vietnam Enterprise Investments Ltd (VEIL) ដែលជាមូលនិធិមួយរបស់ Dragon Capital។ ក្រុមវិនិយោគទាំងពីរនេះសុទ្ធសឹងតែកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុន HAGL។

ការចូលរួមរបស់ IFC ត្រូវបានធ្វើឡើងដោយប្រើប្រាស់ក្របខ័ណ្ឌផ្នែកបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់ពួកគេ។ យោងតាមក្របខ័ណ្ឌនេះ ស្ថាប័នទាំង ឡាយណាដែលទទួលបានមូលនិធិវិនិយោគពី IFC តម្រូវឱ្យអនុវត្តស្របតាមច្បាប់ជាតិ និងកាត់បន្ថយ ឱ្យបានជាអតិបរមាចំពោះផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម (GW 2012-33-35)។

### ការប្រើប្រាស់យន្តការគណនេយ្យភាព

ការិយាល័យភាពអនុលោម ទីប្រឹក្សាដោះស្រាយវិវាទ (CAO) គឺជាយន្តការឧបាស្រ័យឯករាជ្យសម្រាប់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។ ការិយាល័យ CAO ឆ្លើយតបទៅនឹងពាក្យបណ្តឹងពីសហគមន៍ ដែលរងផលប៉ះពាល់ពីគម្រោង។ ការិយាល័យនេះ ធានាឱ្យមានការអនុលោមតាមជាមូលដ្ឋាន និងដោះស្រាយវិវាទដោយប្រើប្រាស់អភិក្រមដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលរួមមានការសម្រុះសម្រួលដោះ ស្រាយវិវាទ ការស្វែងរកការពិតរួមគ្នា ការចែករំលែកព័ត៌មាន និងកិច្ចពិភាក្សាដោយមានការសម្របសម្រួល។

http://www.cao-ombudsman.org/

ចម្ការកៅស៊ូរបស់ក្រុមហ៊ុន HAGL ក្នុងខេត្តរតនៈគិរីបានបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើដីបុព្វបុរសរបស់សហគមន៍ជនជាតិដើមភាគតិច យ៉ាងហោចណាស់ចំនួន ១៤ (ផែនទី ទី១)។ ចម្ការកៅស៊ូរបស់ក្រុមហ៊ុន HAGL បានលេបយក ដីព្រៃ ដីស្រែចម្ការរបស់សហគមន៍ ដីកប់ខ្មោច ដីព្រៃអារក្ស កន្លែងនេសាទ និងដីបម្រុងទុកសម្រាប់មនុស្សជំនាន់ក្រោយ។ ប្រជាពលរដ្ឋនៅក្នុងភូមិបានរួបរួមគ្នាដើម្បីប្រឆាំងទៅនឹងការទន្ទ្រានទាំងនេះ និងទទួលបានត្រឹមតែការមិនគោរពសិទ្ធិរបស់ពួកគេ ការបំភិតបំភ័យ និងការគំរាមប្រព្រឹត្ត អំពើហិង្សាពីសំណាក់អាជ្ញាធរមូលដ្ឋាន និងបុគ្គលិកក្រុមហ៊ុនប៉ុណ្ណោះ។ បណ្តឹងរបស់សហគមន៍អំពីការបាត់បង់ដីធ្លី ទទួលបាននូវការប្រឆាំងតបតដោយ "អង្គហេតុ" ថាតំបន់វិវាទនេះ គឺជាដីរបស់រដ្ឋដែលបានផ្តល់ទៅ ឱ្យក្រុមហ៊ុនដោយស្របច្បាប់ និងមិនមែនជាដីរបស់សហគមន៍ឡើយ។ នៅពេលដែលពាក្យបណ្តឹងនៅមូលដ្ឋាន បានធ្វើឱ្យក្រុមហ៊ុនផ្តល់សំណងសម្រាប់ការខាតបង់ ហើយសំណងដែលផ្តល់ជូននោះមិនគ្រប់គ្រាន់ ប៉ុន្តែអាជ្ញាធរមូលដ្ឋានបានបំភិតបំភ័យសហគមន៍ដោយនិយាយថា "បើមិនយក គឺអត់" ព្រមទាំងគំរាមប្រព្រឹត្តអំពើហិង្សា និងគំរាមចាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍យកទៅដាក់ពន្ធនាគារ (Bugalski & Thuon 2015)។ លើសពីនេះទៀត ការបាត់បង់ដីសហគមន៍ បានធ្វើឱ្យប្រាក់ចំណូលមានការធ្លាក់ចុះ និងបំណុលកើនឡើង ដែលជាហេតុនាំឱ្យជម្លោះមានការកើនឡើង និងបែកបាក់នៅក្នុងសហគមន៍។ អសន្តិសុខស្បៀងដែល បណ្តាលពីការបាត់បង់អនុផលព្រៃឈើ និងដីចម្ការវិលជុំ ត្រូវបានធ្វើឱ្យកាន់តែមានស្ថានភាពធ្ងន់ធ្ងរជាងមុន ដោយសារតែក្រុមហ៊ុនឈូសឆាយព្រៃឈើ ដែលបង្កឲ្យមានទឹកជំនន់ ព្រមទាំងការប្រែប្រួលអាកាសធាតុ និងការកើនឡើងនូវបញ្ហាសុខភាពរបស់សហគមន៍ ជាពិសេសគឺស្ត្រី។

នៅពេលចាប់ផ្តើមកិច្ចអន្តរាគមន៍នៅចុងឆ្នាំ ២០១៣ សហគមន៍មានការធ្លាក់ទឹកចិត្ត និងបែកបាក់គ្នាដោយសារពួកគេគ្មានសង្ឃឹមក្នុងការទទួលបានកិច្ចការពារពីការទន្ទ្រានរបស់ក្រុមហ៊ុន។ កម្លាំងដ៏រឹងមាំចំនួនពីរដែលធ្វើការប្រឆាំងសហគមន៍ ក្នុងនោះរួមមានក្រុមហ៊ុន និងមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។ ការផ្តួចផ្តើមរបស់ IDI/EC បានផ្តល់ក្តីសង្ឃឹមជូនសហគមន៍ ហើយតាមរយៈការផ្តួចផ្តើមនេះ ពួកគេបានកសាងឡើងវិញនូវបណ្តាញសហគមន៍មួយដ៏រឹងមាំ។ ការតស៊ូមតិប្រកបដោយភាពច្នៃប្រឌិតថ្មីរបស់អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ បានជម្រុញឱ្យមានការគៀងគរសហគមន៍ និងសម្រេចបានកិច្ចព្រមព្រៀងស្តីពីក្របខ័ណ្ឌដំណោះស្រាយទូលំទូលាយមួយ ជាមួយក្រុមហ៊ុន HAGL។ ដំណើរការនេះ គឺជាដំណើរការមួយដ៏វែងឆ្ងាយ និងស្មុគស្មាញ ព្រមទាំងត្រូវស្វែងរកមូលនិធិគាំទ្រពីប្រភព ជាច្រើនផ្សេងៗគ្នា។ នៅក្នុងស្ថានភាពដ៏ធ្ងន់ធ្ងរមួយ គឺនៅពេលដែលមានគម្លាតក្នុងការផ្តល់មូលនិធិគាំទ្រ មូលនិធិឆាប់រហ័ស (QDF) របស់គម្រោងអភិបាលកិច្ចដីធ្លីតំបន់មេគង្គ បានជួយឱ្យប្រតិបត្តិការបន្តដំណើរការទៅមុខបាន។ ក្រោយការតស៊ូមតិ និងការចរចារអស់រយៈពេលជាង ២៧ ខែ កន្លងមក នៅពេលកំពុងសរសេររបាយការណ៍នេះ ដំណើរការនេះមិនទាន់បញ្ចប់នៅឡើយទេ។ ប៉ុន្តែបើទោះជាដូច្នេះក្តី គេសម្រេចបាននូវវឌ្ឍនភាពដ៏វិសេសវិសាលមួយ ហើយសម្រាប់ពេលនេះសហគមន៍មូលដ្ឋានមានសុវត្ថិភាពពីការរំលោភបំពានបន្ថែមទៀត។

# សេចក្តីអធិប្បាយអំពីដំណើរការដោះស្រាយវិវាទ

ចាប់តាំងពីពេលចាប់ផ្តើមក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ អន្តរាគមន៍នេះគឺជាដំណើរការដ៏សកម្មមួយ បានធ្វើឱ្យការប្តេជ្ញាចិត្តនៅក្នុងសហគមន៍មានជីវិតឡើងវិញ។ អន្តរាគមន៍នេះ ពឹងផ្អែកទៅលើជំនាញពិសេសៗ និងកិច្ចសហប្រតិបត្តិការរបស់អង្គការផ្សេងៗគ្នាដែលធ្វើការងារតស៊ូមតិ ភាពអត់ធ្មត់ និងប្រសិទ្ធភាពរបស់អ្នកសម្រុះសម្រួលដោះស្រាយវិវាទនៃការិយាល័យ CAO ព្រមទាំងឆន្ទៈរបស់វិនិយោគិន ក្រុមហ៊ុន HAGL ព្រមទាំងវិនិយោគិននៅពេលអនាគតដទៃទៀតក្នុងការដាក់សម្ពាធទៅលើ ក្រុមហ៊ុន និងទាមទារឱ្យក្រុមហ៊ុនប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស។ ដំណើរការនេះអាច ត្រូវបានចម្លងយកទៅអនុវត្តនៅក្នុងស្ថានភាពសមស្រប ដូចមានពិភាក្សាខាងក្រោម ប៉ុន្តែការយល់ដឹងអំពីការអនុវត្តឡើងវិញ និងកម្រងសកម្មភាពគាំទ្រដល់ដំណើរការដ៏វែងឆ្ងាយនេះ គឺជាចំណុចចាប់ផ្តើមមួយដ៏ចាំបាច់។ សំខាន់ជាងនេះទៀត បន្ទាប់ពីការចរចាររយៈពេល ២៧ ខែកន្លងមក អន្តរាគមន៍នេះ មិនទាន់ចប់នៅឡើយ ដោយសារសំណងដែលបានឯកភាពមិនទាន់ត្រូវបានផ្តល់ជូន ដីដែលមិនទាន់បានអភិវឌ្ឍន៍ ដែលត្រូវប្រគល់ទៅឱ្យសហគមន៍វិញ បានវាស់វែង ចុះហត្ថលេខា និងវាយត្រានៅកម្រិតថ្នាក់ខេត្ត ប៉ុន្តែឯកសារនៅកម្រិតថ្នាក់ជាតិ មិនទាន់បញ្ចប់រួចរាល់នៅឡើយ ហើយនៅមានការងារគួរឱ្យកត់សម្គាល់មួយចំនួនទៀតដែលត្រូវធ្វើទាក់ទងនឹងការធ្វើផែនទីសហគមន៍ ព្រមទាំងការចរចារដោយប្រុងប្រយ័ត្នអំពីបញ្ហាប្រព្រឹត្តកម្មទឹក ការប្រគល់មកវិញនូវដីដែលបានអភិវឌ្ឍន៍រួចរាល់ និងការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព។

សម្រាប់ប្រតិបត្តិការកន្លងមក និងប្រតិបត្តិការកំពុងបន្តនៃការផ្តួចផ្តើមនេះ អង្គការមិនមែនរដ្ឋាភិបាលនីមួយៗមានតួនាទីជាក់លាក់របស់ខ្លួន ដោយអង្គការនីមួយៗបាននាំមកនូវជំនាញជាក់លាក់នៅក្នុងដំណើរការចរចារនេះ។ កិច្ចគាំទ្រ និងដំបូន្មានរបស់អ្នកជំនាញនៃអង្គការដែលធ្វើការងារតស៊ូមតិ គឺជាសមាសភាគមួយដ៏សំខាន់ដែលបានជួយពន្លឿនដំណើរការនៅពេលចាប់ផ្តើមដំបូង ព្រមទាំងនឹងបន្តពិនិត្យមើលរហូតដល់ពេលបញ្ចប់។ អង្គការ IDI មានជំនាញឯកទេសក្នុងការប្រើប្រាស់យន្តការគណនេយ្យភាពអន្តរជាតិ និងការបញ្ចុះបញ្ចូលក្រុមហ៊ុន និងស្ថាប័នហិរញ្ញវត្ថុនៅកម្រិតខ្ពស់បំផុត។ អង្គការ EC គឺជាអង្គការមួយដែលមាន បទពិសោធន៍ផ្តល់ការបណ្តុះបណ្តាល និងគៀងគរសហគមន៍មូលដ្ឋានប្រកបដោយជោគជ័យ ដើម្បីតតាំងទៅនឹងក្រុមហ៊ុនធំៗក្នុងប្រទេសកម្ពុជា។ អង្គការ IDI និង EC ក៏បានទាក់ទងអង្គការជនជាតិដើមភាគតិច ដែលធ្វើការងារតស៊ូមតិក្នុងខេត្តរតនៈគិរី ហើយទទួលបានការជឿទុកចិត្តពីសហគមន៍រងផលប៉ះពាល់ផងដែរ។

ការងារដ៏ល្អិតល្អន់មួយចំនួនត្រូវបានធ្វើឡើង អាស្រ័យដោយវាមានភាពចាំបាច់ ដើម្បីចងក្រង និងរៀបចំសហគមន៍សម្រាប់ការផ្តួចផ្តើមនេះ ហើយអង្គការមិនមែនរដ្ឋាភិបាលដៃគូថ្នាក់មូលដ្ឋាន ក៏មានសារៈសំខាន់ផងដែរ ប៉ុន្តែមិនមែនអង្គការទាំងអស់សុទ្ធតែគាំទ្រអន្តរាគមន៍នេះឡើយ។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនមានការភ័យខ្លាចក្នុងការប្រឈមមុខជាមួយក្រុមហ៊ុន។ អង្គការសកម្មជនមួយ ត្រូវបានអាជ្ញាធរខេត្តបណ្តេញចេញរួចទៅហើយ ដោយសារតែការដេញដោលអំពីនីត្យានុកូលភាពរបស់ក្រុមហ៊ុន។ អង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមគាំទ្រពាក្យបណ្តឹងរួមមានអង្គការសមាគមខ្មែរលើ (HA) សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA) បណ្តាញ

សមាជិកសកម្មរបស់ជនជាតិដើមភាគតិច (IRAM) និងមានការប្តេជ្ញាចិត្តចូលរួមក្រោយមកទៀតពីមជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ (ADIC) ។ អង្គការទាំងអស់នេះមានឆន្ទៈចូលរួមនៅក្នុងអង្គភាពដែលមានអនុភាពនេះ និងជាការអង្គការដែលមានជំនាញចាំបាច់។ ជំនាញទាំងនេះ រួមមានសមត្ថភាពពិសេសក្នុងការប្រាស្រ័យទាក់ទងជាមួយសហគមន៍ផ្សេងៗដែលនៅរាយប៉ាយគ្នា និងមានភាសាជនជាតិដើមភាគតិចចំនួន ៧ ខុសៗគ្នា។ ចំណុចនេះគឺលើសពីការបកប្រែភាសា ដោយសារវាពាក់ព័ន្ធទៅនឹងការបកប្រែអត្ថបទ និងការបកប្រែផ្ទាល់មាត់សម្រាប់សហគមន៍ និងវប្បធម៌របស់សាជីវកម្មហិរញ្ញវត្ថុ និងការសម្រុះសម្រួលដោះស្រាយវិវាទអន្តរជាតិ។ ទោះបីជាពួកគេមានជំនាញឯកទេសក៏ដោយ ដៃគូថ្នាក់មូលដ្ឋានក៏ត្រូវការការកសាងសមត្ថភាពទូលំទូលាយផងដែរ ដើម្បីឱ្យពួកគេអាចយល់ដឹងអំពីបញ្ហាប្រឈមនៃការចរចារជាមួយក្រុមហ៊ុនមួយដែលមានអំណាច។

អភិក្រមអន្តរាគមន៍នៃការបញ្ចុះបញ្ចូលវិនិយោគិនក្រុមហ៊ុន HAGL ឱ្យដាក់សម្ពាធលើក្រុមហ៊ុននេះ ត្រូវបានសហគមន៍មើលឃើញថា ជាការណែនាំនូវឧបករណ៍ដ៏មានឥទ្ធិពលសម្រាប់លើកឡើងអំពីការព្រួយបារម្ភរបស់ពួកគេ។ បើទោះជាដូច្នេះក្តី ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងការបកប្រែភាសាអំពីដំណើរការផ្នែកច្បាប់ គឺជាបញ្ហាប្រឈមមួយ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមមួយដែលធំជាងនេះទៀត គឺការពាំនាំសហគមន៍ដែលធ្លាក់ទឹកចិត្តឱ្យធ្វើដំណើរជាមួយគ្នាឆ្ពោះទៅរកគោលដៅរួមមួយ។ ក្រោយរយៈពេល ៥ឆ្នាំ ដែលក្រុមហ៊ុនបានរំលោភបំពាន ដោយមានការសមគំនិតពីអាជ្ញាធរមូលដ្ឋាន បានធ្វើឱ្យសហគមន៍មានការនឿយហត់។ បន្ថែមពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលបានធ្វើឱ្យសហគមន៍មានការរួបរួមគ្នាបន្ថែមទៀតដោយមិនដឹងខ្លួន តាមរយៈការផ្តល់មូលនិធិគាំទ្រគម្រោងគោលដៅជាក់លាក់ ដល់អតិថិជនរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានបង្កើតឱ្យមានជាក្រុមតូចៗ ជំនួសឱ្យសហគមន៍រួម ដែលមានទស្សនវិស័យ និងគោលបំណងរួមគ្នា។ ជាចុងក្រោយ និងសំខាន់ផងដែរនោះ មានមនុស្សជាច្រើន ភ័យខ្លាចក្រុមហ៊ុន និងសង្ស័យចំពោះប្រសិទ្ធភាពនៃអន្តរាគមន៍។

អង្គការ IDI និង EC បានរៀបចំកិច្ចប្រជុំចំនួនពីរបន្តបន្ទាប់គ្នា ដើម្បីពន្យល់ជូនដល់តំណាងសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ថាតើ IFC គឺជាអ្វី? តើអន្តរការីហិរញ្ញវត្ថុ គឺជាអ្វី? តើ ការិយាល័យ CAO គឺជាអ្វី? និងតើគេមានបំណងដាក់សម្ពាធទៅលើក្រុមហ៊ុនឱ្យគោរពសិទ្ធិមនុស្សរបស់សហគមន៍ ដោយរបៀបណា? ក្នុងអំឡុងពេលនៃកិច្ចប្រជុំទាំងនេះ បុគ្គលិករបស់អង្គការសមាគមខ្មែរលើ បានជួយធ្វើការបកប្រែ ធ្វើកិច្ចពិភាក្សា បកប្រែឡើងវិញ និងពន្យល់អំពីគោលគំនិតនានាដោយប្រុងប្រយ័ត្ន។ ក្រោយពីអនុវត្តលំហាត់ផ្សព្វផ្សាយលើកទីមួយ វាបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា គេត្រូវការឱ្យមានឧបករណ៍ផ្សព្វផ្សាយថ្មីៗបន្ថែមទៀត។ ដោយមានកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិមួយទៀត IDI បានផលិតឯកសារព័ត៌មានអំពីកិច្ចប្រជុំ ដែលត្រូវបានបកប្រែជាភាសាជនជាតិដើមភាគតិចចំនួនបួន ក្នុងចំណោមភាសាចំនួនប្រាំពីរ ព្រមទាំងបានបង្កើតជាស្លាយរូបភាពសម្រាប់បញ្ចាំងផងដែរ។ ដើម្បីធ្វើការផ្សព្វផ្សាយ គេបានបោះពុម្ពស្លាយទាំងនោះ និងផលិតជាវីដេអូមួយ ដែលពន្យល់អំពីដំណើរការលម្អិតទាំងនេះ ដោយប្រើប្រាស់ភាសាច្បាស់ៗ សម្រាប់ធ្វើការចែករំលែកជាមួយសហគមន៍។ សិក្ខាសាលាណែនាំ ចំនួនពីរ បានរៀបចំឡើងក្នុងខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១៣ ព្រមទាំងមានការប្រាស្រ័យទាក់ទងជាច្រើនពីសហគមន៍ ដើម្បីជួយដល់ការផ្សព្វផ្សាយផងដែរ។

សហគមន៍មិនមែនជាក្រុមដែលមានរចនាសម្ព័ន្ធដូចគ្នានោះទេ ហើយមានការងារជាច្រើនត្រូវបានធ្វើនៅក្រៅសិក្ខាសាលា។ ការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស (HRIA) បានធ្វើឡើងដោយ អង្គការ IDI និង EC ដែលមានប្រសិទ្ធភាពជាពិសេស ក្នុងការប្រមូលសម្លេងរបស់ស្ត្រី ដែលជាញឹកញាប់ពួកគេតែងមានភាពស្ទាក់ស្ទើរក្នុងការទទួលយកតួនាទីដឹកនាំនៅក្នុងដំណើរការទាំងនេះ។ ការវាយតម្លៃអំពីផលប៉ះពាល់សិទ្ធិមនុស្ស និងកិច្ចខិតខំផ្សព្វផ្សាយតាមរយៈសិក្ខាសាលា នាំឱ្យទទួលបានសម្លេង និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ផ្សេងៗគ្នាពីក្រុមហ៊ុន។ បុគ្គលជាច្រើនលើសលប់ដែលរងផលប៉ះពាល់ មានការព្រួយបារម្ភចំពោះការថែរក្សាដីចម្ការវិលជុំ និងដីព្រៃសហគមន៍ ។ ប៉ុន្តែក្នុងនោះក៏មាន ការព្រួយបារម្ភដទៃទៀតផងដែរ ឧទាហរណ៍ បុគ្គលមួយចំនួនបានទទួលប្រយោជន៍បន្តិចបន្តួចតាមរយៈការងារនៅក្នុងចម្ការកៅស៊ូ ដោយឡែក បុគ្គលដទៃទៀតបានចូលរួមសកម្មភាពកាប់ឈើខុសច្បាប់ដើម្បីទទួលបានប្រាក់កម្រៃ។ បញ្ហាប័ណ្ណកម្មសិទ្ធិដីសមូហភាព នៅតែបន្តគ្មានការដោះស្រាយ ដោយសារសមាជិកសហគមន៍មួយចំនួនឱ្យតម្លៃទៅលើផលប្រយោជន៍ប្រកបដោយសក្តានុពលផ្នែកសុវត្ថិភាពដីធ្លី និងផ្នែកហិរញ្ញវត្ថុ នៃប័ណ្ណកម្មសិទ្ធិដីជាលក្ខណៈបុគ្គល ខណៈពេលដែលសមាជិកសហគមន៍ដទៃទៀត រាប់បញ្ចូលទាំងតំណាងសហគមន៍ផងដែរ គាំទ្រចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។

បើទោះបីជាមានការរំពឹងទុកខុសៗគ្នាក៏ដោយ សមាជិកសហគមន៍ភាគច្រើន ដែលមកពីភូមិរងផលប៉ះពាល់ទាំងអស់បានឯកភាពថាពួកគេចង់ការពារដីរបស់ពួកគេ និងការពារធនធានព្រៃឈើរបស់ពួកគេពីក្រុមហ៊ុន។ ក្រោយពេលផ្សព្វផ្សាយព័ត៌មានតាមរយៈសិក្ខាសាលា ក្រុមពិភាក្សា និងខ្សែភាពយន្តជូនដល់បណ្តាភូមិទាំងអស់ តំណាងសហគមន៍ បានធ្វើការសាកសួរ និងទទួលបានការយល់ព្រមពីសហគមន៍របស់ពួកគេ ឱ្យបន្តដំណើរការបណ្តឹងជាមួយការិយាល័យ CAO។ ក្នុងខែកុម្ភៈ ឆ្នាំ២០១៤ អង្គការ IDI និង EC បានដាក់ពាក្យបណ្តឹងរួមគ្នា និងបាននាំតំណាងសហគមន៍ចំនួន ១៧រូប មកពីសហគមន៍រងផលប៉ះពាល់ ទៅរាជធានីភ្នំពេញ ដើម្បីជួបជាមួយ IFC និងប្រាប់ពួកគេដោយផ្ទាល់អំពីការព្រួយបារម្ភរបស់សហគមន៍ (ភូមិចំនួន៣ ត្រូវបានក្រុមហ៊ុន HAGL បញ្ជាក់ថាពុំមានរងផលប៉ះពាល់ និងបានដកខ្លួនចេញពីពាក្យបណ្តឹង ដោយបន្សល់តែសហគមន៍ចំនួន ១៤)។ នៅថ្ងៃបន្ទាប់គេបានដាក់ពាក្យបណ្តឹងជាផ្លូវការ និងរៀបចំធ្វើសន្និសីទសារព័ត៌មានមួយ ដែលដឹកនាំដោយតំណាងសហគមន៍។

តំណាងរបស់ក្រុមហ៊ុន HAGL បានទាក់ទងអង្គការ IDI ភ្លាមៗ ក្រោយពេលដែលអង្គការធ្វើការងារតស៊ូមតិ បានដាក់ពាក្យបណ្តឹងទៅការិយាល័យ CAO និង បានបញ្ជូនពាក្យបណ្តឹងមួយច្បាប់ទៅក្រុមហ៊ុន Dragon Capital។ នៅក្នុងកិច្ចប្រជុំមួយក្នុងរាជធានីភ្នំពេញ តំណាងរបស់ក្រុមហ៊ុន បានបង្ហាញអំពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការដោះស្រាយបណ្តឹងសារទុក្ខរបស់ប្រជាពលរដ្ឋ និងព្យាយាមបញ្ចុះបញ្ចូលក្រុមតស៊ូមតិឱ្យទៅខេត្តរតនៈគិរីជាមួយពួកគេ ដោយពួកគេបាននិយាយថាពួកគេនឹង "ដោះស្រាយបញ្ហាភ្លាម"។ ការសង្ស័យថាក្រុមហ៊ុន HAGL ចង់ដោះស្រាយបញ្ហានេះតាមរយៈការទូទាត់សំណងឆាប់រហ័ស និងប្រហែលជាតាមរយៈការបំភិតបំភ័យដូចដែលក្រុមហ៊ុនបានធ្វើកន្លងមក នៅក្នុងការចរចារជាមួយសហគមន៍មូលដ្ឋាន ដូច្នេះ ក្រុមអង្គការមិនមែនរដ្ឋាភិបាល បានជម្រុញឱ្យតំណាងក្រុមហ៊ុនសហការជាមួយដំណើរការរបស់ការិយាល័យ CAO។ សហគមន៍មួយចំនួនដែលបានពាក់ព័ន្ធ និងភាពស្មុគស្មាញនៃបណ្តឹងសារទុក្ខ ព្រមទាំងការរំលោភបំពានសិទ្ធិមនុស្ស មានន័យថាគេចាំបាច់ត្រូវការឱ្យមានដំណើរការដោះស្រាយវិវាទមួយដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ។ តំណាងក្រុមហ៊ុន មានភាពស្ទាក់ស្ទើរ

ប៉ុន្តែចុងក្រោយបានឯកភាព។ ក្រុមហ៊ុន និងអង្គការដែលគាំទ្រ ទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុដោយខ្លួនឯង សម្រាប់ការចូលរួមរបស់ពួកគេនៅក្នុងការចរចារ ប៉ុន្តែការិយាល័យ CAO ទទួលបានកិច្ចគាំទ្រផ្នែក ហិរញ្ញវត្ថុពី IFC ហើយថ្លៃចំណាយនៃការសម្រុះសម្រួលដោះស្រាយវិវាទដោយផ្ទាល់នេះ ពុំមែនជាបន្ទុកខាងភាគីក្រុមហ៊ុន ឬអង្គការដែលគាំទ្រឡើយ។ ការិយាល័យCAO ក៏បានចំណាយថវិការបស់ខ្លួនដើម្បីនាំសមាជិកសហគមន៍ឱ្យចូលរួមនៅក្នុងការចរចារផងដែរ។

នៅពេលដែលដំណើរការចរចារបានចាប់ផ្តើម អង្គការ IDI, EC និង Global Witness បានចូលរួមជាមួយវិនិយោគិនសំខាន់ៗរបស់ក្រុមហ៊ុន HAGL និង វិនិយោគិនដទៃទៀតនៃក្រុមហ៊ុននេះនៅពេលអនាគត ដើម្បីបន្តជូនដំណឹងដល់ពួកគេ និងជម្រុញឱ្យពួកគេប្រើប្រាស់ឥទ្ធិពលរបស់ពួកគេ ដើម្បីបញ្ចុះបញ្ចូលក្រុមហ៊ុន HAGL ឱ្យដោះស្រាយបញ្ហារំលោភបំពានសិទ្ធិមនុស្សរបស់ពួកគេក្នុងប្រទេសកម្ពុជា។ វិនិយោគិន ជាច្រើនបានផ្តល់ការឆ្លើយតបជាវិជ្ជមាន ហើយអន្តរាគមន៍របស់ពួកគេ បានក្លាយជាធាតុផ្សំមួយដ៏សំខាន់ នៅក្នុងការប្តេជ្ញាចិត្តចុងក្រោយរបស់ក្រុមហ៊ុន HAGL (តំណភ្ជាប់ដើម្បីទទួលបានសេចក្តីថ្លែងការណ៍រួមអាចរកមើលនៅទំព័រ ii និងទំព័រ 9) ។ ឆន្ទៈដ៏មោះមុតរបស់បុគ្គលិក IDI ព្រមជាមួយនឹងឆន្ទៈរបស់វិនិយោគិន និងម្ចាស់ភាគហ៊ុន ក្នុងការចូលរួមនៅក្នុងការតស៊ូមតិ ក្រោមទម្រង់បែបនេះ ទីបំផុតបានបង្ខំឱ្យ ក្រុមហ៊ុន HAGL ចូលរួមនៅក្នុងការចរចារយ៉ាងម៉ឺងម៉ាត់។

ការដាក់សម្ពាធទៅលើក្រុមហ៊ុន និងវិនិយោគិនរបស់ពួកគេពីកម្រិតកំពូល និងការបង្កើតឱ្យមានអំណាចនៅក្នុងសហគមន៍មូលដ្ឋានពីខាងក្រោម គឺជាសកម្មភាពមួយប្រកបដោយប្រសិទ្ធភាព ប៉ុន្តែដំណើរការនេះក៏ទទួលរងការបំភិតបំភ័យពីអាជ្ញាធរថ្នាក់មូលដ្ឋានផងដែរ។ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចបឋម របស់អង្គការ EC និងអង្គការសមាគមខ្មែរលើ ពួកគេបានរងការបៀតបៀនពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលភ័យខ្លាចថាអង្គការមិនមែនរដ្ឋាភិបាល មកបំផុសបំផុលឱ្យមានការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន។ តំណាងរបស់ អង្គការសមាគមខ្មែរលើ មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះជាមួយអាជ្ញាធរ ព្រមទាំងបានរៀបចំវិធីដើម្បីជួបជាមួយប្រជាពលរដ្ឋ ដោយជៀសវាងបាននូវការប្រឈមមុខជាមួយអាជ្ញាធរ។ យ៉ាងណាមិញ ក្នុងខែមីនា ឆ្នាំ២០១៥ នៅពេលដែលក្រុមអ្នកសម្រុះសម្រួលដោះស្រាយវិវាទរបស់ការិយាល័យ CAO បានចាប់ផ្តើមចុះធ្វើទស្សនកិច្ចតាមសហគមន៍ និងបានរៀបចំឱ្យមាននូវកិច្ចប្រជុំនានា អភិបាលខេត្ត មិនបានអនុញ្ញាតឱ្យពួកគេធ្វើប្រតិបត្តិការនៅក្នុងខេត្តឡើយ លុះត្រាណាតែការិយាល័យ CAO បានធ្វើការប្រាស្រ័យទាក់ទងជាមួយក្រសួងមហាផ្ទៃ (MoI) និងបានចេញលិខិតជាផ្លូវការមួយ ទើបការរំខានពីអាជ្ញាធរមូលដ្ឋានបានផ្អាកទៅវិញ ដោយត្រូវចំណាយពេលអស់ចំនួន ៥ខែ នៅក្នុងដំណើរការនេះ។

ព្រឹត្តិការណ៍ដ៏សំខាន់មួយទៀត បានកើតឡើងនៅថ្នាក់មូលដ្ឋាន ក្រោយពេលដែលការិយាល័យ CAO បានពិនិត្យឡើងវិញទៅលើករណីនេះ និងបញ្ជាក់អំពីតួនាទីរបស់ពួកគេ ក្នុងនាមជាអ្នកសម្រុះសម្រួលដោះស្រាយវិវាទ។ តំណាងរបស់ការិយាល័យ CAO បានជួបជាមួយតំណាងអ្នកភូមិ ដើម្បីពិភាក្សាអំពីរបៀបនៃដំណើរការសម្រុះសម្រួលដោះស្រាយវិវាទ អ្វីដែលតំណាងអ្នកភូមិអាចរំពឹងទុកថានឹងទទួលបានពីដំណើរការនេះ និងព័ត៌មានកម្រិតថ្នាក់ភូមិប្រភេទណាខ្លះដែលពួកគេត្រូវប្រមូល។ ដំណើរការលម្អិត និងជំនាញឯកទេសដែលត្រូវការ

ឱ្យមានសម្រាប់ចូលរួមនៅក្នុងដំណើរការនេះ បានបណ្តាលឱ្យតំណាងអ្នកភូមិ ដែលមានវ័យចំណាស់មួយចំនួនលាលែងពីតំណែងរបស់ពួកគេ ដោយប្រគល់ភារកិច្ចជាតំណាងអ្នកភូមិទៅឱ្យយុវជនវ័យក្មេងដែលមានជំនាញភាសាខ្មែរប្រសើរជាង និងមានការអប់រំមួយចំនួនជំនួសវិញ។ សិទ្ធិអំណាច និងការដឹកនាំរបស់តំណាងអ្នកភូមិដែលមានវ័យចំណាស់ទាំងនេះ បានបាត់បង់នៅក្នុងរយៈពេល ប៉ុន្មានខែក្រោយមក ជាពិសេសនៅពេលចូលរួមកិច្ចសហប្រតិបត្តិការ និងប្រមូលព័ត៌មាននៅកម្រិតថ្នាក់ភូមិ។

អ្នកសម្រុះសម្រួលដោះស្រាយវិវាទនៃការិយាល័យ CAO គឺជាតួអង្គមួយដ៏សំខាន់ ដោយសារនេះគឺជាការសម្រុះសម្រួលដោះស្រាយវិវាទលើកដំបូងរបស់ពួកគេ វិធានមូលដ្ឋានមួយចំនួនត្រូវបានបង្កើតឡើង។ នៅក្នុងការចរចារលើកដំបូងនេះ អ្នកសម្រុះសម្រួលដោះស្រាយវិវាទបានជម្រុញឱ្យមានវិធានមូលដ្ឋានមិនសមស្របមួយចំនួនដែលធ្វើឱ្យតំណាងផ្នែកច្បាប់នៃអង្គការមិនមែនរដ្ឋាភិបាលស្ថិតនៅម្ខាង និងមានបំណងគាបសង្កត់ទៅលើការប្រាស្រ័យទាក់ទងខាងក្រៅនានាដែលចាំបាច់ ដើម្បីធ្វើឱ្យវិនិយោគិនបន្តទទួលបានការជូនដំណឹង។ ទោះបីជាវិធានមូលដ្ឋានបែបនេះ អាចមានភាពសមស្របនៅក្នុងវិវាទរវាងធុរកិច្ចមួយ និងធុរកិច្ចមួយទៀតក៏ដោយ ប៉ុន្តែវាបានបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើការសម្រុះសម្រួលដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព រវាងសហគមន៍ជនជាតិដើមភាគតិច និងសាជីវកម្មពហុជាតិសាសន៍។ ខណៈពេលដែលដំណើរការនេះមានការវិវឌ្ឍទៅមុខ ការិយាល័យ CAO បានជ្រើសរើសអ្នកសម្រុះសម្រួលដោះស្រាយវិវាទអន្តរជាតិមួយរូបទៀត ដែលមានបទពិសោធន៍ទូលំទូលាយក្នុងការសម្រុះសម្រួលដោះស្រាយវិវាទ ដែលមានលក្ខណៈស្មុគស្មាញបែបនេះ និងយល់អំពីទំនាក់ទំនងអំណាចមិនស្មើភាពគ្នា ដែលជ្រៀតចូលទៅក្នុងការសម្រុះសម្រួលដោះស្រាយវិវាទ ហើយគាត់បានធ្វើការងាររួមគ្នាជាមួយអ្នកសម្រុះសម្រួលដោះស្រាយវិវាទពីដំបូង ដោយបាននាំមកនូវបច្ចេកទេសសមស្រប សម្រាប់បរិបទនេះ។

បុគ្គលិករបស់អង្គការ EC ដែលធ្វើការងារនៅថ្នាក់មូលដ្ឋានក្នុងខេត្តរតនៈគិរី បានធ្វើឱ្យករណីនេះ មានដំណើរការប្រព្រឹត្តទៅត្រូវទៅតាមគន្លង ហើយពួកគេបានដើរតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងទៅលើ សេចក្តីលម្អិតនានា និងសម្របសម្រួលដល់ការប្រាស្រ័យទាក់ទង រវាងសហគមន៍ជាមួយការិយាល័យ CAO។ ទម្ងន់ការងារសម្រាប់ករណីនេះ មានភាពខ្វះចន្លោះ ដោយវាពាក់ព័ន្ធទៅនឹងសកម្មភាពប្រមូលទិន្នន័យ និងវគ្គបណ្តុះបណ្តាលយ៉ាងល្អិតល្អន់ ពីខែវិច្ឆិកា ឆ្នាំ២០១៣ រហូតដល់ខែមេសា ឆ្នាំ២០១៤ នៅពេល ដែលការិយាល័យ CAO បានបញ្ជាក់ឱ្យដឹងអំពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន HAGL។ រហូតដល់ខែមករា ឆ្នាំ២០១៥ ទើបសកម្មភាពបានកើនឡើងជាថ្មីម្តងទៀត និងរហូតដល់ខែកញ្ញា ឆ្នាំ២០១៥ ទើបសម្រេចបាននូវវឌ្ឍនភាពចម្បងមួយ។ រយៈពេលស្ងៀមស្ងាត់មួយទៀត បានបន្តរហូតដល់ខែមីនា ឆ្នាំ២០១៦ ហើយគេក៏មិនទាន់ដឹងនៅឡើយ ថាតើសកម្មភាពនៅក្នុងដំណាក់កាលបន្ទាប់ នឹងមានរយៈពេលប៉ុន្មាន (សូមមើលឧបសម្ព័ន្ធ២ ៖ ក្របខ័ណ្ឌពេលវេលា)។ ករណីនេះបានដាក់បន្ទុកជាច្រើនទៅលើបុគ្គលិករបស់ អង្គការ EC ដោយសារតំរូវការ ការកសាងសមត្ថភាពជាច្រើនសម្រាប់ដៃគូអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងតំណាងសហគមន៍។ មេរៀនដែលបានរៀនសូត្រកន្លងមកត្រូវធ្វើការបូកសរុប ហើយសកម្មភាពសំខាន់ៗនានាទាមទារឱ្យមានការបណ្តុះបណ្តាលឡើងវិញ ពីកម្រងសកម្មភាពមួយទៅកម្រងសកម្មភាពមួយទៀត។ អង្គការ EC បានជួលបុគ្គលិកអចិន្ត្រៃយ៍មួយរូប ឱ្យប្រចាំការនៅខេត្តរតនៈគិរី

ដោយសារការបន្តប្រាស្រ័យទាក់ទងជាមួយសហគមន៍ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាថារាល់ទិន្នន័យចាំបាច់នានាពីសហគមន៍រងផលប៉ះពាល់ ត្រូវបានចងក្រងសម្រាប់ធ្វើការចរចារ។ បុគ្គលិកម្នាក់នេះ បានធ្វើការងារ និងបន្តធ្វើការងារជាមួយសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងការិយាល័យ CAO ដើម្បីប្រមូល និងផ្សព្វផ្សាយព័ត៌មាន រវាងអ្នកពាក់ព័ន្ធទាំងអស់។

សហគមន៍បានទទួលវគ្គបណ្តុះបណ្តាលជាច្រើនអំពីសិទ្ធិដីធ្លី ការចរចារប្រកបដោយប្រសិទ្ធភាព ការប្រមូលទិន្នន័យដែលមានភាពរឹងមាំអំពីផលប៉ះពាល់ដែលពួកគេបានរងគ្រោះពីក្រុមហ៊ុន។ បុគ្គលិករបស់អង្គការ IDI និង EC ត្រូវចំណាយពេលវេលាជិត ៣ខែ ដើម្បីបង្រៀននិងណែនាំតំណាងសហគមន៍ ដោយប្រុងប្រយ័ត្ន អំពីរបៀបអភិវឌ្ឍបញ្ជីសារពើភ័ណ្ឌនៃការខាតបង់ទាំងកម្រិតសមូហភាព និងកម្រិតគ្រួសារ។ បញ្ជីសារពើភ័ណ្ឌដែលដឹកនាំធ្វើដោយសហគមន៍ និងការទាមទារសំណងដែលឆ្លើយតបទៅនឹងសារពើភ័ណ្ឌទាំងនោះ ដោយភ្ជាប់មកជាមួយនូវផែនទីគូរដោយដៃដែលផ្តល់រូបភាពតំណាងឲ្យតំបន់រងផលប៉ះពាល់ (ឧបសម្ព័ន្ធ១ ៖ ផែនទី ទី២ និងទី៣)។

បញ្ជីសារពើភ័ណ្ឌទាំងនេះ បានបំពេញបន្ថែមទៅលើការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស (HRIA) ព្រមទាំងបានផ្តល់នូវមូលដ្ឋានភស្តុតាងដ៏រឹងមាំមួយសម្រាប់ការចរចារ។ តំណាងសហគមន៍ បានប្រើប្រាស់បញ្ជីសារពើភ័ណ្ឌ និងផែនទីទាំងនេះ នៅក្នុងកិច្ចប្រជុំនានា ដើម្បីបង្ហាញអំពីករណីរបស់ពួកគេទៅ ក្រុមហ៊ុន HAGL។ ការងារធ្វើផែនទី និងបញ្ជីសារពើភ័ណ្ឌដោយប្រុងប្រយ័ត្ន និងលម្អិតនេះ បានប្រមូលផ្តុំសម្លេងរបស់សហគមន៍រួមបញ្ចូលគ្នា ហើយវគ្គបណ្តុះបណ្តាលអំពីការចរចារ បានជួយពង្រឹងពួកគេបន្ថែមទៀត។

នៅក្នុងការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនកន្លងមក តំណាងសហគមន៍ស្ទើរតែមិនអាចសម្លឹងមើលមុខមនុស្សដែលតំណាងឲ្យក្រុមហ៊ុន។ រចនាសម្ព័ន្ធឋានានុក្រមនៅក្នុងប្រទេសកម្ពុជាមិនសូវមានភាពបត់បែនឡើយ ហើយប្រជាពលរដ្ឋក្នុងភូមិដែលមិនទទួលបានការអប់រំ គឺជាអ្នកដែលស្ថិតនៅផ្នែកខាងក្រោមគេបំផុតនៃប្រព័ន្ធនេះ។ ក្រោយពេលដែលអង្គការ EC និង IDI បានផ្តល់វគ្គបណ្តុះបណ្តាលដ៏ល្អិតល្អន់ជាច្រើនរួចមក តំណាងសហគមន៍ហ៊ានងើបឈរដោយស្មើមុខនៅចំពោះមុខតំណាងក្រុមហ៊ុន ព្រមទាំងប្រាប់ទៅកាន់តំណាងក្រុមហ៊ុនយ៉ាងច្បាស់ៗ ថាដីបុព្វបុរសរបស់ពួកគេស្ថិតនៅកន្លែងណា ព្រមទាំងបានបង្ហាញ អំពីផលប៉ះពាល់នៃការអភិវឌ្ឍចម្ការកៅស៊ូរបស់ក្រុមហ៊ុន HAGL។ នេះគឺជាសមិទ្ធិផលចម្បងមួយ ព្រមទាំងមានឥទ្ធិពលដ៏ខ្លាំងក្លាទៅលើអ្នកចរចាររបស់ភាគីក្រុមហ៊ុន។

ក្រោយពេលកិច្ចប្រជុំរួមគ្នាដែលសម្រុះសម្រួលដោយការិយាល័យ CAO ក្នុងខែកញ្ញា ឆ្នាំ២០១៥ តំណាងក្រុមហ៊ុន HAGL បានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ថានឹងមិនធ្វើការឈូសឆាយឬ ធ្វើការអភិវឌ្ឍណាមួយបន្ថែមទៀតទៅលើសម្បទានដីសេដ្ឋកិច្ចរបស់ខ្លួនឡើយ ព្រមទាំងប្រគល់ទៅឱ្យសហគមន៍វិញនូវដី និងព្រៃឈើសេសសល់ដែលមិនទាន់បានអភិវឌ្ឍន៍ (សូមមើលតំណភ្ជាប់ខាង ក្រោមសម្រាប់សេចក្តីថ្លែងការណ៍រួម)។ សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអានអូរយ៉ាដាវ ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ ត្រូវបានកាត់បន្ថយចំនួន ១៣.៧២០ ហិកតា (ពី១៦.៨៤៩ ហិកតា មកត្រឹម ៣.១២៩ ហិកតា)។

ទោះបីជាសម្រេចបាននូវកិច្ចព្រមព្រៀងគួរឱ្យកត់សម្គាល់នេះជាមួយក្រុមហ៊ុន HAGL ក៏ដោយ ប៉ុន្តែនៅតែមានបញ្ហាប្រឈមចម្បងៗសេសសល់មួយចំនួនទៀតផងដែរ។ បច្ចុប្បន្ន ដំណើរការនេះកំពុងស្ថិតនៅក្នុងដំណាក់កាលសំខាន់មួយ ដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការពីរាជរដ្ឋាភិបាល។ ការកត់សម្គាល់ដ៏សំខាន់នោះ គឺឯកសារស្តីពីការកាត់បន្ថយ សម្បទានដីសេដ្ឋកិច្ច ត្រូវបានចុះហត្ថលេខានៅកម្រិតថ្នាក់ខេត្ត ប៉ុន្តែមិនទាន់ទទួលបានការអនុម័តពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) នៅឡើយ។ ក្រសួងមហាផ្ទៃបានផ្តល់កិច្ចគាំទ្រ និងយល់អំពីសារៈសំខាន់នៃដំណើរការនេះ។ ទោះជាដូច្នេះក្តី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនសូវផ្តល់ការគាំទ្រឡើយ ព្រមទាំងបានលើកឡើងនូវការព្រួយបារម្ភអំពីការដែលការិយាល័យ CAO រំលោភបំពាន ទៅលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា។ ប្រសិនបើពុំមានការគាំទ្រពីរាជរដ្ឋាភិបាលទៅលើសេចក្តីសម្រេចទាំងនេះទេនោះ ដំណើរការសម្រុះសម្រួលដោះស្រាយវិវាទនេះអាចជាប់គាំង។ ទោះបីជាមាន ការឯកភាពពីភាគីក្រុមហ៊ុនក៏ដោយ រាជរដ្ឋាភិបាលត្រូវទទួលស្គាល់តាមផ្លូវច្បាប់ទៅលើការកាត់បន្ថយ សម្បទានដីសេដ្ឋកិច្ច និងការវិភាជឡើងវិញ ដើម្បីឱ្យសហគមន៍អាចទទួលបានដីរបស់ពួកគេត្រឡប់ មកវិញ។ ការិយាល័យ CAO បានផ្តល់ការបណ្តុះបណ្តាលជូនមន្ត្រីរដ្ឋាភិបាល អំពីការសម្រុះសម្រួល/ការដោះស្រាយវិវាទ ដែលអាចបង្កើនការយល់ដឹង និងឆន្ទៈរបស់ពួកគេក្នុងការគាំទ្រដល់ កិច្ចព្រមព្រៀងនេះ។ គេត្រូវរង់ចាំ មើលថាតើរាល់ស្ថាប័នរដ្ឋាភិបាលទាំងអស់ដែលពាក់ព័ន្ធ នឹងគាំទ្រដល់កិច្ចព្រមព្រៀងដែលសម្រេចបាន និងសហការនៅក្នុងការអនុវត្តកិច្ចព្រមព្រៀងទាំងនេះដែរឬទេ។

# លទ្ធផល/ធាតុចេញសំខាន់ៗ

## ការកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន

### *វគ្គបណ្តុះបណ្តាលដែលមានការចូលរួមពីសហគមន៍និងតំណាងអង្គការមិនមែនរដ្ឋាភិបាល*

- សិក្ខាសាលាមួយរយៈពេលមួយថ្ងៃសម្រាប់អង្គការថ្នាក់មូលដ្ឋាន បានពន្យល់អំពីព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ Rubber Barons របស់ Global Witness កម្មសិទ្ធិរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលទទួលបានសម្បទានដីសេដ្ឋកិច្ចជាច្រើនក្នុងខេត្តរតនៈគិរី ស្ថាប័នដែលផ្តល់កិច្ចគាំទ្រហិរញ្ញវត្ថុដល់ក្រុមហ៊ុនហុងអាញ់យាឡាយ រាប់បញ្ចូលទាំង IFC គោលនយោបាយស្តីពីកិច្ចការពារផ្នែកសង្គម និងបរិស្ថាន និងយន្តការគណនេយ្យភាពរបស់ IFC និង ការិយាល័យ CAO។

- សិក្ខាសាលាមួយនៅពេលក្រោយមកទៀត បានផ្តល់ព័ត៌មានដូចគ្នាសម្រាប់តំណាងសហគមន៍ ប៉ុន្តែមានការកែសម្រួលមួយចំនួនដើម្បីបញ្ចូលស្លាយដែលមានរូបភាពពន្យល់ ព្រមជាមួយនឹងសារខ្លីៗ និងច្បាស់ៗ។ អង្គការ IDI និង EC បានសហការជាមួយអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV) ដើម្បីប្រែក្លាយការបង្ហាញស្លាយទៅជាខ្សែអាត់វីដេអូជីវចលមួយរយៈពេល ២៣ នាទី ដោយបញ្ចូលសម្លេងភាសាជនជាតិដើមភាគតិចចំនួន ៤ ភាសា សម្រាប់ធ្វើការផ្សព្វផ្សាយនៅតាមភូមិ។

- ការបណ្តុះបណ្តាលអំពីសិទ្ធិដីធ្លី និងសិទ្ធិមនុស្សរបស់សហគមន៍ជនជាតិដើមភាគតិច ដោយមានបទបង្ហាញពីតំណាងសហគមន៍ដទៃទៀតក្នុងប្រទេសកម្ពុជា ដែលបានដាក់ពាក្យបណ្តឹងប្រកបដោយជោគជ័យ។

- ការបណ្តុះបណ្តាលអំពីការចរចារ (វគ្គបណ្តុះបណ្តាលចំនួនពីរផ្សេងៗគ្នា" ដោយប្រើប្រាស់ ឧបករណ៍បណ្តុះបណ្តាលដែលត្រូវបានអភិវឌ្ឍន៍ឡើងយ៉ាងពិសេស ដែលមានចំណងជើងថា *ការបញ្ចៀសការបណ្តេញចេញដោយបង្ខំ ៖ សៀវភៅណែនាំសម្រាប់សហគមន៍អំពីការចរចារ និងការតស៊ូមតិ*។

- កិច្ចប្រជុំ និងការពិគ្រោះយោបល់មុនពេល និងក្រោយពេលចរចារទាំងអស់ ដើម្បីបង្ហាញអំពីបញ្ជីសារពើភ័ណ្ឌ និងការទាមទាររបស់សហគមន៍ចំពោះក្រុមហ៊ុនហុងអាញ់យាឡាយ។

- សិក្ខាសាលាស្តីពី "ជម្រើសនានាសម្រាប់កិច្ចព្រមព្រៀងដែលអាចធ្វើទៅបាន" បានផ្តល់ឧទាហរណ៍មួយចំនួនពីបណ្តាប្រទេសដទៃទៀត ដែលសម្រេចបានតាមរយៈការដោះស្រាយវិវាទដីធ្លី ដែលមានលក្ខណៈស្រដៀងគ្នានេះ។

- សិក្ខាសាលាស្តីពីការធ្វើផែនទីភូមិ និងការប្រើប្រាស់ឧបករណ៍ GPS។

*សកម្មភាពនៅថ្នាក់ភូមិ*

- ការវាយតម្លៃលម្អិតទៅលើផលប៉ះពាល់ ត្រូវបានធ្វើឡើងជា៤ដំណាក់កាល ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៣ រហូតដល់ខែមីនា ឆ្នាំ២០១៤។

- អង្គការ IDI និង EC បានធ្វើការសិក្សា និងផលិតបាននូវការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្សលម្អិតមួយ។ ដោយមានកិច្ចគាំទ្រផ្នែកភស្តុភារ និងការបកប្រែភាសាពីអង្គការសមាគមខ្មែរលើ អង្គការ EC បានដឹកនាំធ្វើការស្រាវជ្រាវជាក់ស្តែងដោយបានចុះធ្វើទស្សនកិច្ចភូមិចំនួន ២៥។ ក្រុមស្រាវជ្រាវនេះបានធ្វើកិច្ចសម្ភាសន៍ "អ្នកផ្តល់ព័ត៌មានសំខាន់" ចំនួន ២៤ កិច្ចសម្ភាសន៍គ្រួសារនីមួយៗចំនួន ១១០ ការធ្វើលំហាត់កំណត់ផែនទីសហគមន៍ដោយមានការចូលរួមចំនួន ២៣ ក្រុមពិភាក្សាតាមសហគមន៍ចំនួន ២៣ និងកិច្ចពិភាក្សាជាមួយក្រុមស្ត្រីចំនួន ២៣។ អង្គការ IDI និង EC បានសរសេររបាយការណ៍គ្រប់ជ្រុងជ្រោយមួយដែលមានកម្រាស់ ៨០ ទំព័រ និងបានធ្វើការបោះពុម្ពផ្សាយក្នុងពាក់កណ្តាលឆ្នាំ២០១៤។ របាយការណ៍នេះត្រូវបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់កិច្ចពិភាក្សាសម្រុះសម្រួលដោះស្រាយវិវាទ ប៉ុន្តែរបាយការណ៍នេះមិនទាន់ត្រូវបានប្រកាសផ្សព្វផ្សាយ ឬចែកចាយនៅឡើយទេ ដោយសារតែការសម្រុះសម្រួលដោះស្រាយវិវាទកំពុងបន្ត។

- ការចុះធ្វើការស្រាវជ្រាវតាមភូមិជាមួយក្រុមការងារនៃការិយាល័យ CAO អង្គការ EC និង អង្គការដៃគូ ក្នុងខែកុម្ភៈ ឆ្នាំ២០១៥។

- ពួកគេបានចុះធ្វើទស្សនកិច្ចទៅតាមភូមិនីមួយៗ ដើម្បីពន្យល់អំពីដំណើរការរបស់ការិយាល័យ CAO និងប្រមូលព័ត៌មានជាក់លាក់ ទាក់ទងនឹងការខាតបង់របស់សហគមន៍ ព្រមទាំងបញ្ហាដែលត្រូវដោះស្រាយ។ តំណាងសហគមន៍នីមួយៗត្រូវបានប្រគល់ភារកិច្ចឱ្យរៀបចំបញ្ជីសារពើភ័ណ្ឌអំពីការខាតបង់ និងផលប៉ះពាល់នៅកម្រិតថ្នាក់ភូមិ និងដំណោះស្រាយសម្រាប់ការខាតបង់ និងផលប៉ះពាល់ទាំងនោះ។

- ផែនទីភូមិ និងបញ្ជីសារពើភ័ណ្ឌសហគមន៍ ត្រូវបានបង្កើតឡើងក្នុងខែសីហា ឆ្នាំ២០១៥។

- អង្គការ EC ដោយមានកិច្ចគាំទ្រពីអង្គការដៃគូនៅថ្នាក់មូលដ្ឋាន បានចុះធ្វើទស្សនកិច្ចទៅតាមភូមិនីមួយៗ ដើម្បីជួយដល់សហគមន៍ក្នុងការគូសគំនូសព្រៀងផែនទីបែបប្រពៃណី ដែលបង្ហាញអំពី ព្រំប្រទល់ភូមិ ការប្រើប្រាស់ដី និងលក្ខណៈពិសេសនៃធនធានធម្មជាតិ ព្រមទាំងតំបន់ទាំងឡាយណាដែលរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។

- ជំនាញថ្មីៗត្រូវបានបង្កើតឡើងសម្រាប់អង្គការជនជាតិដើមភាគតិច ដែលធ្វើការតស៊ូមតិ នៅថ្នាក់មូលដ្ឋាន។

  ឥឡូវនេះ អង្គការជនជាតិដើមភាគតិចមានបទពិសោធន៍ ក្នុងការចូលរួមជាមួយយន្តការរបស់ការិយាល័យ

CAO និង ដឹងថាការចូលរួមបែបនេះ គឺអាចធ្វើទៅបាន។ ពួកគេបាន ទទួលការណែនាំ និងអនុវត្តជំនាញចរចារ និងជំនាញរៀបចំចាត់ចែង ដ៏មានតម្លៃដទៃទៀត តាមរយៈដំណើរការនេះ។

អង្គការមួយចំនួន ដូចជាអង្គការសមាគមខ្មែរលើ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការគាំទ្រសហគមន៍ ដើម្បីត្រួតពិនិត្យលទ្ធផលការងារនៅពេលអនាគត ការចរចារ និង កិច្ចព្រមព្រៀងចុងក្រោយ ដែលមានការឯកភាពជាមួយក្រុមហ៊ុនហុងអាញ់យាឡាយ។ ការងារសេសសល់ជាច្រើនទៀតដែលត្រូវធ្វើ ដូចជាការធ្វើលំហាត់កំណត់ផែនទីរួមគ្នាជាមួយក្រុមហ៊ុនហ៊ងអានយ៉ាឡាយ និងមន្ត្រីរដ្ឋាភិបាល ការរៀបចំសហគមន៍សម្រាប់ធ្វើលំហាត់ទាំងនេះ ការធ្វើការចរចារ និងកិច្ចព្រមព្រៀងដាច់ដោយឡែកសម្រាប់ភូមិនីមួយៗ ព្រមទាំងលទ្ធភាពក្នុងការចរចារអំពីការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពផងដែរ។ បន្ថែមពីនេះទៀត ក្រុមហ៊ុនហុងអាញ់យាឡាយ ត្រូវតែបន្តស្ថិតក្រោមការត្រួតពិនិត្យ បើទោះបីជាក្រោយពេលដែលកិច្ចព្រមព្រៀងត្រូវបានអនុវត្តក៏ដោយ។ វាមានការពិបាកក្នុងការដឹងថា តើអង្គការថ្នាក់មូលដ្ឋាននឹងត្រូវការកិច្ចគាំទ្រច្រើនប៉ុណ្ណាពីអង្គការ IDI និង EC សម្រាប់ដំណាក់កាលបន្តបន្ទាប់ទៀតនៃគម្រោងនេះ។ អង្គការថ្នាក់មូលដ្ឋានបានទទួលជំនាញមួយចំនួន ហើយពួកគេនិយាយប្រកបដោយទំនុកចិត្តអំពីសមត្ថភាពថ្មីៗរបស់ពួកគេ ប៉ុន្តែសមត្ថភាពដែលត្រូវកែលម្អបន្ថែមទៀតសម្រាប់អង្គការតូចៗទាំងនេះ អាចនៅមានកម្រិតគួរឱ្យកត់សម្គាល់។

- សមាជិកសហគមន៍មូលដ្ឋានបានទទួលការបណ្តុះបណ្តាលអំពីការចរចារ និងការប្រមូលទិន្នន័យ។

ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពយ៉ាងល្អិតល្អន់ អំពីសិទ្ធិដីធ្លី និងជំនាញចរចារ បានធ្វើឱ្យតំណាងសហគមន៍ឈរយ៉ាងរឹងមាំ នៅចំពោះមុខតំណាងក្រុមហ៊ុនដែលមានអំណាច ដើម្បីថ្លែងអំពីការទាមទាររបស់ពួកគេ និងនិយាយការពារខ្លួនឯងតាមរយៈការបង្ហាញអំពី សិទ្ធិស្របច្បាប់របស់ពួកគេ។ ពួកគេបានទទួលការយល់ដឹងផងដែរ អំពីរបៀបកំណត់ឱ្យបាន ច្បាស់លាស់អំពី "បញ្ហា" និង ធ្វើបញ្ជីសារពើភ័ណ្ឌអំពីការខាតបង់នានាដែលឆ្លើយតបទៅនឹងការទាមទាររបស់ពួកគេ ក្នុងលក្ខណៈមួយដែលមានភាពច្បាស់លាស់ ដើម្បីស្វែងរកសំណងត្រឡប់មកវិញ។ ទោះជាដូច្នេះក្តី ជំនាញទាំងនេះពុំមានភាពរឹងមាំឡើយ ដោយសមាជិកមួយចំនួនមានទំនុកចិត្តជាងសមាជិកដទៃទៀត ចំពោះសមត្ថភាពថ្មីៗរបស់ពួកគេ។ សូម្បីតែតំណាងសហគមន៍ដែលមានភាពជឿជាក់ខ្លាំងបំផុតក៏នឹង "ស្វែងរកអង្គការមួយ ដើម្បីជួយដល់ពួកគេ" ផងដែរក្នុងករណីដែលពួកគេត្រូវការចម្លងដំណើរការនេះទៅអនុវត្តនៅក្នុងករណីដទៃទៀត។

## កិច្ចប្រជុំសម្រុះសម្រួលដោះស្រាយវិវាទ និងការប្តេជ្ញាចិត្តរបស់ភាគីក្រុមហ៊ុន

ពាក្យបណ្តឹងដែលបានដាក់ជូនទៅការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (CAO) របស់ IFC ត្រូវបានធ្វើឡើងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤។ ពាក្យបណ្តឹងទាំងស្រុង អាចរកបាន នៅទីនេះ ៖

http://www.inclusivedevelopment.net/wp-content/uploads/2014/02/Complaint-to-CAO-re-Dragon-Capital-HAGL-.pdf

- ក្នុងខែមករា ឆ្នាំ២០១៥ ការិយាល័យ CAO បានសម្របសម្រួលឱ្យមានកិច្ចប្រជុំរួមលើកដំបូងមួយជាមួយក្រុមហ៊ុនហុងអាញ់យាឡាយ។ នៅក្នុងកិច្ចប្រជុំមួយទៀតនាថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ តំណាងសហគមន៍មួយចំនួនដែលបានជ្រើសរើស បានក្រោកឈរឡើងដើម្បីបង្ហាញអំពី "ការទាមទារជាសមូហភាព" របស់ភូមិទាំង ១៤ ទៅកាន់តំណាងរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។

- ក្រុមហ៊ុនហុងអាញ់យាឡាយ បានផ្តល់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ដែលការឆ្លើយតបនេះ ត្រូវបានចែករំលែកជាមួយតំណាងសហគមន៍ នៅថ្ងៃទី២៧-២៨ ខែមីនា ឆ្នាំ២០១៥។

- បញ្ជីសារពើភ័ណ្ឌរបស់ភូមិនីមួយៗអំពីការខាតបង់ និង ការទាមទារ ដើម្បីឱ្យមានដំណោះស្រាយចំពោះបញ្ហាខាតបង់ទាំងនោះ ត្រូវបានផ្តល់ជូនទៅឱ្យភាគីក្រុមហ៊ុនហុងអាញ់យាឡាយ ក្នុងរយៈពេលជាច្រើនខែ។

- នៅថ្ងៃទី១៥-១៦ និង ១៧-១៩ ខែកញ្ញា ឆ្នាំ២០១៥ ភូមិនីមួយៗក្នុងចំណោមភូមិទាំង១៤ បានបង្ហាញផែនទីគំនូសព្រៀងរបស់ពួកគេ ទៅក្រុមហ៊ុនហុងអាញ់យាឡាយ និងតំណាងក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់ពួកគេ នៅក្នុងកិច្ចប្រជុំរួមមួយដែលសម្រុះសម្រួលដោយការិយាល័យ CAO។ បន្ទាប់ពីការចរចារដ៏ល្អិតល្អន់មួយចំនួន តំណាងរបស់ក្រុមហ៊ុនហុងអាញ់យាឡាយបានបញ្ជាក់ជាផ្លូវការអំពី ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនថានឹងមិនធ្វើការឈូសឆាយ ឬ អភិវឌ្ឍន៍បន្តទៀត ទៅលើសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ដែលមានជាអាទិ៍ ក្រុមហ៊ុនហេងប្រាឌ័រ ក្រុមហ៊ុន ស៊ី អ ឌី និងក្រុមហ៊ុនហ៊ែងអានអូរយ៉ាដាវ ព្រមទាំងប្រគល់មកវិញនូវដី និងព្រៃឈើសេសសល់ ដែលមិនទាន់បានអភិវឌ្ឍន៍ ដែលក្រុមហ៊ុនប៉ាន់ប្រមាណថាមានទំហំជាង ១០.០០០ ហិកតា។ ការប្តេជ្ញាចិត្តទាំងនេះ បានធ្វើឡើងនៅក្នុងលិខិតចំនួន២ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៥ និង ចុះហត្ថលេខាដោយអគ្គនាយករបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។ នៅក្នុងលិខិតទី១ ក្រុមហ៊ុនហុងអាញ់យាឡាយ បានយល់ព្រមមិនធ្វើការឈូសឆាយ ឬ អភិវឌ្ឍន៍ទៅលើដីរបស់ភូមិកាជូត ភូមិកេត និងភូមិណាយ ដែលកន្លងមក ប្រឈមទៅនឹងការបាត់បង់ដីរបស់ពួកគេ ដោយសារតែការពង្រីកចម្ការកៅស៊ូរបស់ក្រុមហ៊ុន។ ការប្តេជ្ញាចិត្តស្រដៀងគ្នានេះ ត្រូវបានធ្វើឡើងនៅក្នុងលិខិតទី២ សម្រាប់ភូមិចំនួន ១១ ដែលបានរងផលប៉ះពាល់រួចទៅហើយ (ភូមិក្រេះ ភូមិកាំ ភូមិម៉ាស់ ភូមិតាឡាវ ភូមិអ៊ីន ភូមិម៉ាលិក ភូមិកាណាតធំ ភូមិកាក់ ភូមិតាណង ភូមិមុយ និងភូមិពែង) ដើម្បីជៀសវាងបង្កផលប៉ះពាល់អវិជ្ជមានបន្ថែមទៀត។

  នៅក្នុងកិច្ចប្រជុំក្នុងខេត្តសៀមរាប (កាលពីថ្ងៃទី១៥-១៩ ខែកញ្ញា ឆ្នាំ២០១៥) ទទួលបានកិច្ចព្រមព្រៀងគួរឱ្យកត់សម្គាល់មួយចំនួនបន្ថែមទៀត ជាមួយភូមិទាំង១១ ដែលបានបាត់បង់ដី និងធនធានរួចទៅហើយ ដោយសារតែចម្ការកៅស៊ូរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។ កិច្ចព្រមព្រៀងទាំងនោះ រួមមាន ៖

- ក្រុមហ៊ុនហុងអាញ់យាឡាយ ព្រមព្រៀងប្រើផលិតផលគីមីដែលស្របតាមបទបញ្ញត្តិ បរិស្ថានតែប៉ុណ្ណោះ។

- ក្រុមហ៊ុនហុងអាញ់យាឡាយ ព្រមព្រៀងជួសជុល និងថែទាំផ្លូវ និងស្ពានដែលអ្នកភូមិប្រើ ដែលទទួលរងផលប៉ះពាល់ ដោយប្រតិបត្តិការរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។

- គូភាគីបានយល់ព្រមធ្វើទស្សនកិច្ចរួមគ្នា ព្រមជាមួយនឹងអ្នកពាក់ព័ន្ធដទៃទៀត ដែលរួមមាន អង្គការមិនមែនរដ្ឋាភិបាលដែលជាទីប្រឹក្សា ការិយាល័យ CAO និងអាជ្ញាធរមូលដ្ឋាន ទៅភូមិនីមួយៗទាំង ១១ ដែលរងផលប៉ះពាល់ ដើម្បីកំណត់ព្រំប្រទល់នៃចម្ការរបស់ ក្រុមហ៊ុនហុងអាញ់យាឡាយ និងព្រំប្រទល់នៃភូមិដែលរងផលប៉ះពាល់ ដើម្បីកំណត់ព្រំប្រទល់។

- ប្រសិនបើតាមរយៈការធ្វើទស្សនកិច្ចរួមគ្នារកឃើញថា ក្រុមហ៊ុនហុងអាញ់យាឡាយ បានឈូសឆាយ និងអភិវឌ្ឍដី និង ធនធានដែលសហគមន៍បានប្រើប្រាស់តាមបែបវិធានប្រពៃណី នោះក្រុមហ៊ុននឹង (ក) ផ្តល់សំណងដល់ភូមិសម្រាប់ដីនេះ និង (ខ) ប្រសិនបើអ្នកភូមិមិនព្រមទទួលយកសំណងទេ ក្រុមហ៊ុនហុងអាញ់យាឡាយ នឹងប្រគល់ដីជូនអ្នកភូមិវិញ និង

- ក្រុមហ៊ុនហុងអាញ់យាឡាយ យល់ព្រមផ្តល់ការគាំទ្រដល់អ្នកភូមិក្នុងការស្នើសុំប័ណ្ណកម្មសិទ្ធិដីរបស់ពួកគេ។

- ក្រុមហ៊ុនហុងអាញ់យាឡាយ យល់ព្រមស្តារឡើងវិញនូវប្រភពទឹកដែលរងផលប៉ះពាល់ រួមទាំងធនធានត្រីដែលបានបាត់បង់សម្រាប់ភូមិទាំង ១៤។

- ក្រុមហ៊ុនហុងអាញ់យាឡាយ ក៏បានព្រមព្រៀងផងដែរ ក្នុងការអនុម័តយន្តការប្រតិបត្តិការបណ្តឹងសារទុក្ខទាក់ទងនឹងប្រតិបត្តិការកសិពាណិជ្ជកម្មរបស់ពួកគេក្នុងប្រទេសកម្ពុជា។

  សេចក្តីថ្លែងការណ៍រួមទាំងនេះ អាចរកបានតាមរយៈតំណភ្ជាប់ខាងក្រោម ៖

  http://www.inclusivedevelopment.net/wp-content/uploads/2015/09/Joint-Statement-Villages-Group-2-16-Sept-2015-EngKh4clean-SS-1.pdf

  http://www.inclusivedevelopment.net/wp-content/uploads/2015/09/Joint-Statement-Villages - Group-3-19-Sept-2015-Eng.pdf

## ឧបករណ៍ និងធនធានដែលបានផលិត និងប្រើប្រាស់

- ខ្សែភាពយន្តដែលផ្តល់ការពន្យល់អំពីឧស្សាហកម្មកៅស៊ូ និង របៀបដែល IFC មានទំនាក់ទំនង ជាមួយក្រុមហ៊ុនហុងអាញ់យាឡាយ តាមរយៈអន្តរការីហិរញ្ញវត្ថុមួយ ត្រូវបានបកប្រែជាភាសា ជនជាតិដើមភាគតិចចំនួន ៤ ភាសា និង ផ្តល់ជូនទៅឱ្យសហគមន៍នីមួយៗ ក្នុងទម្រង់ជាវីស៊ីឌី។

- ករណីនេះបានប្រើប្រាស់ឧបករណ៍បណ្តុះបណ្តាលជាច្រើន ដែលអង្គការ EC និង IDI បានអភិវឌ្ឍន៍ ៖
  *ការបញ្ចៀសការបណ្តេញចេញដោយបង្ខំ៖ សៀវភៅណែនាំសម្រាប់សហគមន៍ អំពីការចរចារ និងការតស៊ូមតិ*

  http://www.inclusivedevelopment.net/resources/publications/

*"សៀវភៅណែនាំសម្រាប់ការតស៊ូមតិលើការងារតាមដានប្រភពថវិកា"*

http://www.inclusivedevelopment.net/wp-content/uploads/2015/09/Following-the-Money.pdf

*"សៀវភៅណែនាំស្តីពីសម្បទានដីសេដ្ឋកិច្ច"*

http://www.equitablecambodia.org/website/

*"សៀវភៅណែនាំស្តីពីការការពារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន"*

http://www.inclusivedevelopment.net/wp-content/uploads/2015/09/CG-Book-1_final1.pdf

## ការផ្សព្វផ្សាយ

- របាយការណ៍មួយត្រូវបានបោះពុម្ពផ្សាយរួមគ្នាដោយអង្គការអុកស្វាម IDI និង EC អំពីបញ្ហាកង្វះតម្លាភាព គណនេយ្យភាព និងការឃ្លាំមើលទៅលើការវិនិយោគនៃអន្តរការីហិរញ្ញវត្ថុរបស់ IFC។ របាយការណ៍នេះមានចំណងជើងថា "ទុក្ខវេទនារបស់អ្នកដទៃ" (The Suffering of Others) ព្រមទាំងបានទទួលការគ្រប ដណ្តប់ពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិយ៉ាងទូលំទូលាយ និងទទួលបានការឆ្លើយតបកម្រិតខ្ពស់ពី IFC។

  https://www.oxfam.org/sites/www.oxfam.org/files/file_attachments/ib-suffering-of-others-international-finance-corporation-020415-en.pdf

- ឯកសារមួយរៀបរាប់លម្អិតទាក់ទងនឹងការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស ដែលមានចំណងជើងថា *ការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស នៃសម្បទានដីសេដ្ឋកិច្ច របស់ក្រុមហ៊ុនហុងអាញ់យាឡាយ ក្នុងខេត្តរតនៈគិរី* ត្រូវបានយកមកបង្ហាញនៅឯសន្និសីទអន្តរជាតិមួយស្តីពីការទន្ទ្រានយកដីនៅឯសាកលវិទ្យាល័យឈាងម៉ៃ ក្នុងខែមិថុនា ឆ្នាំ២០១៥។

  http://www.iss.nl/fileadmin/ASSETS/iss/Research_and_projects/Research_networks/LDPI/CMCP_28-_Bugalski___Ratha.pdf

- ក្នុងនោះក៏មានសមិទ្ធិផលចម្បងៗនៃការដោះស្រាយបញ្ហាក្នុងមូលដ្ឋានផងដែរ ៖

  http://mrlg.org/resources/major-breakthrough-in-cambodia-mediation/

  http://www.inclusivedevelopment.net/cambodia-and-laos-hagl-rubber-plantations/

  http://www.phnompenhpost.com/national/hagl-makes-deal-villagers

- ដោយសារតែករណីនេះមិនទាន់បានដោះស្រាយទាំងស្រុង ដូច្នេះការផ្សព្វផ្សាយព័ត៌មានលើសពីនេះ ពុំមានភាពសមស្របឡើយ។

## ការកំណត់ករណីគំរូ សម្រាប់វិនិយោគិនអន្តរជាតិ

ឥឡូវនេះ ករណីយុត្តិសាស្ត្រត្រូវបានកំណត់សម្រាប់វិនិយោគិនធំៗ ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស គោលនយោបាយស្តីពីផលប៉ះពាល់បរិស្ថាន របស់ពួកគេ និងការប្តេជ្ញាចិត្តនានា ក្នុងការគោរពទៅតាមច្បាប់ របស់ប្រទេសជាម្ចាស់ផ្ទះ។ IFC បានចូលរួមកិច្ចប្រជុំរួមគ្នា ដែលសម្រុះសម្រួលដោយការិយាល័យ CAO កាលពីខែកញ្ញា ឆ្នាំ២០១៥ ក្នុងនាមជាអ្នកសង្កេតការណ៍ ដែលបានផ្តល់ឱកាសឱ្យ IFC ស្តាប់ឮពីសហគមន៍ អំពីផលប៉ះពាល់នៃគម្រោងវិនិយោគរបស់ពួកគេ។

# មេរៀនបទពិសោធន៍ដែលបានរៀនសូត្រ

## ទំនាក់ទំនងនៃវិសមភាពអំណាច

ចំណុចសំខាន់នៃការផ្តួចផ្តើមនេះ គឺជាការសម្រុះសម្រួល និងការចរចារដោះស្រាយវិវាទ អំពីទំនាក់ទំនងនៃវិសមភាពអំណាច។ ពុំមាននរណាម្នាក់ប្រាកដក្នុងចិត្តឡើយថាការសម្រុះសម្រួលដោះស្រាយវិវាទរវាងសហគមន៍ជនជាតិដើមភាគតិច និងសាជីវកម្មអន្តរជាតិមួយដែលមានអំណាច អាចប្រព្រឹត្តធ្វើទៅបាន។ ទីបំផុត ការតស៊ូមតិរបស់វិនិយោគិន និងការសម្រុះសម្រួលដោះស្រាយវិវាទដោយប្រុងប្រយ័ត្ន បានបង្ហាញឱ្យឃើញថាមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយអតុល្យភាពអំណាចទាំងនោះ និងការចរចារ ដោយផ្អែកលើមូលដ្ឋានផលប្រយោជន៍ ពិតជាធានាបាននូវសំណងប្រកបដោយអត្ថន័យ។ យុទ្ធសាស្ត្រនេះបានធ្វើឱ្យក្រុមហ៊ុនបាត់បង់ទំនុកចិត្តពីដំបូង ថាពួកគេអាចដោះស្រាយបញ្ហាតាមរយៈកិច្ចប្រជុំ ទល់មុខគ្នានៅឯកម្រិតថ្នាក់ភូមិ។ ពួកគេត្រូវបានបង្ខំឱ្យដោះស្រាយអំពើរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងររបស់ពួកគេ តាមរយៈការចរចារដែលកាន់តែមានតុល្យភាព។

ទោះបីជាដូច្នេះក្តី ដំណើរការនេះពុំមានភាពរលូនឡើយ ហើយហានិភ័យនៃការផ្តួចផ្តើមពីលើចុះក្រោមក៏មិនធ្លាប់មានដែរ។ ដំណើរការនេះបានទាមទារឱ្យមានកិច្ចខំប្រឹងប្រែងដ៏ពិតប្រាកដ ដើម្បីបង្កើតឲ្យបាននូវដំណើរការសម្រុះសម្រួលដោះស្រាយវិវាទមួយ ដែលអាចប្រឈមមុខ ជំនួនឲ្យការកើតឡើងវិញ នូវអតុល្យភាពអំណាច។ អំណាចរបស់អាជ្ញាធរមូលដ្ឋាន បានគំរាមកំហែងឱ្យចុះខ្សោយនូវសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល និងសេរីភាពរបស់សហគមន៍។ អតុល្យភាពនៃអំណាចបានកើតមានឡើងរវាងស្ថាប័ន និងកម្រិតជំនាញរបស់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ ផងដែរ។ ក្នុងនោះក៏មានការប្រកួតប្រជែងអំណាចរវាងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងសហគមន៍ដែលពួកគតស៊ូមតិឲ្យផងដែរ។ បុគ្គលិករបស់ EC មួយរូបបានប្រាប់ឱ្យដឹងថា មេរៀនដែលសំខាន់បំផុត គឺត្រូវដឹងថាអ្នកដែលមកពីទីក្រុង [បុគ្គលិករបស់អង្គការ EC] "មិនយល់នោះឡើយ..... យើងត្រូវទៅជួបអ្នកភូមិដល់កន្លែង យើងត្រូវសិក្សាពីអ្នកភូមិជាមុន។ នៅពេលដែលយើងយល់អំពីពួកគេ ទើបពួកគេអាចចូលរួមក្នុងកម្មវិធីបាន។" ការយល់ដឹងតាមរយៈភាសាជាច្រើន និងអ្នកសម្រុះសម្រួលដោះស្រាយវិវាទច្រើន មានការលំបាកខ្លាំងណាស់។

⇒ **អង្គការដែលផ្តល់ការគាំទ្រ ត្រូវចាក់ឫសគល់ និងចំណាយពេលវេលាមួយចំនួននៅក្នុងសហគមន៍រងផលប៉ះពាល់ ដើម្បីអាចយល់អំពីការយល់ឃើញរបស់សហគមន៍ទាំងនោះ**

ការយល់ដឹងអំពីការយល់ឃើញរបស់អ្នកភូមិ គឺជាយុទ្ធសាស្ត្រមួយដែលបានប្រើប្រាស់ដោយអ្នកសម្រុះសម្រួលដោះស្រាយវិវាទរបស់ការិយាល័យ CAO ដោយបានស្នើសុំឱ្យតំណាងក្រុមហ៊ុន ក្រឡេកមើលទៅកាន់ពិភពលោកក្នុងលក្ខណៈមួយខុសពីមុន និង ដើម្បីស្វែងយល់អំពីផលប៉ះពាល់ ដែលក្រុមហ៊ុនរបស់ពួកគេបានបង្កទៅលើប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ការស្នើសុំឱ្យតំណាងរបស់ក្រុមហ៊ុន គោរពចំពោះជីវិត និងជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច ការស្នើសុំឱ្យអាជ្ញាធរមូលដ្ឋាន អនុវត្តស្របតាមដំណើរការនេះ និងការជម្រុញឱ្យបុគ្គលិកអង្គការមិនរដ្ឋាភិបាល មើលឃើញអ្វីៗតាមរយៈការឆ្លុះបញ្ចាំងទៅលើការយល់ឃើញរបស់ប្រជាពលរដ្ឋក្នុង

ភូមិ គឺជាធាតុផ្សំទាំងឡាយដែលនាំឱ្យមានការផ្លាស់ប្តូរតុល្យភាពនៃអំណាច។ ជាដំបូង ចាប់ផ្តើមជាមួយនឹងកម្លាំងតាមរយៈការតស៊ូមតិពីវិនិយោគិន បន្ទាប់មក តាមរយៈការប្រាស្រ័យទាក់ទង និងការប៉ុនប៉ងឱ្យមានការយោគយល់ និង ជឿទុកចិត្តគ្នាទៅវិញទៅមក។

⇒ **វាមានសារៈសំខាន់ដែលត្រូវមានអ្នកសម្រុះសម្រួលដោះស្រាយវិវាទមួយរូបប្រកបដោយគុណវុឌ្ឍិខ្ពស់ ហើយយល់អំពីអតុល្យភាពអំណាច**

## ការប្តេជ្ញាចិត្តរបស់សហគមន៍

ការផ្តល់នូវអ្វីដែលតំណាងភូមិបានរៀនសូត្រនៅឯសិក្ខាសាលាជាមួយអង្គការ IDI និង EC ទៅដល់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ នៅក្នុងភូមិរបស់ពួកគេ គឺជាបញ្ហាប្រឈមមួយដោយសារមូលហេតុជាច្រើន។ ដំបូង ពួកគេត្រូវបង្កើតឱ្យមានភាពរំភើប និង ការប្តេជ្ញាចិត្តនៅក្នុងសហគមន៍មួយដែលរងការបាក់ស្មារតីដើម្បីក្រោកឡើងប្រឆាំងនឹងក្រុមហ៊ុន *ជាថ្មីម្តងទៀត*។ អ្វីដែលបានជម្រុញទឹកចិត្តប្រជាពលរដ្ឋ គឺជាភាពច្នៃប្រឌិតថ្មីនៃអភិក្រមនេះ ហើយវាមានភាពសមស្រប។ ពួកគេបានឃើញភ្លាមៗថា ការដាក់សម្ពាធទៅលើក្រុមហ៊ុនតាមរយៈយន្តការគណនេយ្យភាពរបស់វិនិយោគិន អាចធ្វើឱ្យមានភាពខុសគ្នាមួយ។ បើទោះជាដូច្នេះក្តី នៅតែមានសមាជិកសហគមន៍មួយចំនួនតូចដែលមិនចូលរួមនៅក្នុងគំនិតផ្តួចផ្តើមនេះ ដោយសមាជិកសហគមន៍មួយភាគតូច បានចូលរួមនៅក្នុងការជួញដូរឈើខុសច្បាប់ និងសមាជិកសហគមន៍មួយចំនួនទៀតចង់រក្សាប័ណ្ណកម្មសិទ្ធិដីឯកជនរបស់ពួកគេ ដើម្បីឱ្យពួកគេអាចទទួលបានប្រាក់កម្ចី ឬលក់ដីរបស់ពួកគេបាន។

ការចរចារអំពីភាពខុសគ្នាទាំងនេះពុំមានការលំបាកអ្វីឡើយ អាស្រ័យដោយសមាជិកសហគមន៍ដ៏ច្រើនលើសលប់ បានរួបរួមនៅក្នុងគោលបំណងរបស់ពួកគេ។ ការពន្យល់អំពីសេចក្តីលម្អិតនៃដំណើរការថ្មីនេះជូនដល់អ្នកភូមិ មានការលំបាកខ្លាំងណាស់។ តំណាងសហគមន៍បានយល់អំពីគោលគំនិតពីសិក្ខាសាលាទាំងឡាយ ប៉ុន្តែគោលគំនិតទាំងនេះក៏ថ្មីផងដែរសម្រាប់ពួកគេ និងមានផ្នែកមួយចំនួន ដែលពិបាកយល់។ ខ្សែភាពយន្តគឺជាឧបករណ៍មួយដ៏ល្អ ប៉ុន្តែកង្វះអគ្គិសនី និងឧបករណ៍នៅតំបន់ជាច្រើន បានធ្វើឱ្យការប្រាស្រ័យទាក់ទងដោយផ្ទាល់ និង កិច្ចពិភាក្សាលម្អិត មានសារៈសំខាន់យ៉ាងខ្លាំងនៅកម្រិតថ្នាក់ភូមិ។ ស្លាយដែលបានបោះពុម្ពចេញពីបទបង្ហាញ មានសារៈប្រយោជន៍ ប៉ុន្តែតំណាងសហគមន៍ បានប្រាប់ឱ្យដឹងថា ស្លាយទាំងនោះនៅតែមានអក្សរច្រើន ហើយសហគមន៍បានសួរសំណួរជាច្រើន។ តំណាងរបស់អង្គការសមាគមខ្មែរលើ បានសម្របសម្រួលកិច្ចប្រជុំជាច្រើននៅក្នុងភូមិ។

តំណាងសហគមន៍ គឺជាចំណុចប្រាស្រ័យទាក់ទងមួយដ៏សំខាន់ រវាងអង្គការមិនមែនរដ្ឋាភិបាល ការិយាល័យ CAO និង សមាជិកសហគមន៍ដទៃទៀត។ ចាស់ព្រឹទ្ធាចារ្យ ដែលបានលាលែងចេញពីតំណែងរបស់ពួកគេ ដើម្បីអនុញ្ញាតិឱ្យយុវជនដែលមានការអប់រំល្អប្រសើរ ធ្វើជាតំណាងសហគមន៍ជំនួសពួកគេវិញ គឺជាអ្នកដែលពូកែប្រាស្រ័យទាក់ទង និងពូកែធ្វើការរៀបចំជាងយុវជនដែលជំនួសពួកគេ កត្តានេះបានបង្កឱ្យមានការប្រឈមមួយចំនួនពាក់ព័ន្ធនឹងការគៀងគរសហគមន៍ ការផ្សព្វផ្សាយព័ត៌មាន និងការប្រមូលទិន្នន័យ។

សហគមន៍មួយចំនួនក្នុងចំណោមសហគមន៍ទាំងនេះ ត្រូវការឱ្យមានជំនួយបន្ថែមពីអង្គការមិនមែនរដ្ឋាភិបាលដៃគូ ដែលនេះគឺជាការលំបាកមួយ ប៉ុន្តែជារួម វាស្ថិតនៅក្នុងស្ថានភាពមួយដែលអាចគ្រប់គ្រងបាន។ ឧបសគ្គចម្បងមួយទៀត គឺទីកន្លែងដាច់ស្រយាល និងមានចំនួនភូមិច្រើន ដោយភូមិសរុបពីដំបូងមានចំនួន ១៧ភូមិ និងក្រោយការស៊ើបអង្កេតបឋម នៅសល់ចំនួន ១៤ភូមិ។ នៅរដូវវស្សា មានការលំបាកខ្លាំងណាស់ក្នុងការ ធ្វើដំណើរទៅកាន់ភូមិទាំងនោះ។

⇒ **នៅក្នុងដំណើរការបែបនេះ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើការងារជាមួយមេដឹកនាំប្រពៃណី។ ប្រសិនបើគេត្រូវការឱ្យមានយុវជនវ័យក្មេងដើម្បីសម្របសម្រួលការប្រាស្រ័យទាក់ទងជាមួយពិភពខាងក្រៅ ពួកគេគប្បីស្ថិតនៅក្រោមសិទ្ធិអំណាច (និងរាយការណ៍ជូន) ចាស់ព្រឹទ្ធាចារ្យ។**

## តម្រូវការពេលវេលា និងភាពមោះមុត

ការបង្កើតឱ្យមានទំនុកចិត្តរបស់សហគមន៍ដែលរងផលប៉ះពាល់ និងមេដឹកនាំរបស់ពួកគេ បានចំណាយពេលវេលាជាច្រើនគួរឱ្យកត់សម្គាល់ក្នុងការផ្តល់ការបណ្តុះបណ្តាល និងគាំទ្រពួកគេ។ ការរៀបចំ ការសម្រុះសម្រួលដោះស្រាយវិវាទ និង ការប្រមូលទិន្នន័យ ក៏ជាដំណើរការមួយដែលចំណាយពេលវេលាច្រើនផងដែរ។ ការវងចាំ និងសកម្មភាពដ៏ល្អិតល្អន់ មានរយៈពេលវែងផងដែរ។ លទ្ធផលដែលសម្រេចបាននៅពេលនេះ មិនអាចសម្រេចក្នុងរយៈពេលដ៏ខ្លីជាងនេះបានឡើយ។ កន្លងមក ដំណើរការទាំងមូលបានចំណាយពេលអស់ ២៧ខែ និងមិនទាន់បញ្ចប់នៅឡើយ។

⇒ **ត្រូវត្រៀមខ្លួនឱ្យបានរួចរាល់សម្រាប់ដំណើរដ៏វែងឆ្ងាយ**

## ការធ្វើផែនទីសហគមន៍

គ្រប់ភាគីទាំងអស់នៅកម្រិតមូលដ្ឋាន មានអារម្មណ៍ថាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើលំហាត់នេះ ហើយតំណាងសហគមន៍មួយចំនួន មានការលំបាកក្នុងការអនុវត្តឱ្យស្របទៅតាមផែនការ និងយុទ្ធសាស្ត្រ។ ជាញឹកញាប់ ការប្រមូលទិន្នន័យសំខាន់ៗសម្រាប់ដំណើរការនេះ ទាមទារឱ្យមានជំនាញថ្មីៗ សម្រាប់តំណាងសហគមន៍។ បន្ថែមពីនេះទៀត តំណាងសហគមន៍ មិនមែងតែងតែជាចាស់ព្រឹទ្ធាចារ្យ នៅក្នុងភូមិនោះទេ ដូច្នេះពួកគេពុំមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការប្រមូលព័ត៌មានដែលត្រូវការ ឱ្យបានទាន់ពេលវេលាឡើយ។

⇒ **វិភាជន៍ធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ដើម្បីជួយដល់តំណាងសហគមន៍នៅក្នុងភារកិច្ចចងក្រងអំពីធនធាន និង ការធ្វើផែនទី។**

## ការសម្របសម្រួល និងការប្រាស្រ័យទាក់ទងដោយអង្គការមិនមែនរដ្ឋាភិបាល

វាមានសារៈសំខាន់ខ្លាំងណាស់ដែលត្រូវមានដៃគូជាច្រើនដែលមានជំនាញខុសៗគ្នា ដើម្បីអនុវត្តអន្តរាគមន៍នេះ ប៉ុន្តែការដាក់បញ្ចូលឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋានចំនួនបួន ហាក់បីដូចជាចំនួនច្រើនពេក។ ការដែលមានដៃគូកម្រិតមូលដ្ឋានមួយដែលរឹងមាំ អាចមានប្រសិទ្ធភាពជាង។ អង្គការ IDI បន្តជូនដំណឹងដល់អង្គការសមធម៌កម្ពុជា អំពីរូបភាពធំទូលាយនៃសកម្មភាពតស៊ូមតិ និងសេចក្តីសម្រេចចិត្តជាយុទ្ធសាស្ត្រ ហើយអង្គការសមធម៌កម្ពុជា បានសម្របសម្រួលជាមួយការិយាល័យ CAO និងអង្គការមិនមែនរដ្ឋាភិបាលដៃគូថ្នាក់មូលដ្ឋាន។ អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ខ្វះសមត្ថភាពផ្នែកស្ថាប័ន ក្នុងការគ្រប់គ្រងរាល់ការងារផ្សព្វផ្សាយ និងការរៀបចំដែលចាំបាច់សម្រាប់គម្រោងនេះ ហើយការអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេបានបង្ហាញឱ្យឃើញថាជាការខាតបង់ ជំនួសឱ្យការផ្តល់ជាប្រយោជន៍ចំពោះគម្រោង។ បន្ថែមពីនេះទៀត បើទោះបីជាអង្គការនីមួយៗមានវិស័យជំនាញឯកទេសរៀងៗខ្លួន និងមានភារកិច្ចជាក់លាក់សម្រាប់ប្រតិបត្តិការនេះក៏ដោយ ប៉ុន្តែការបន្តរក្សាគណនេយ្យភាពដែលមានភាពត្រួតស៊ីគ្នា គឺជាបញ្ហាប្រឈមមួយដ៏លំបាក។ បន្ទាប់ពីការចរចារជុំទីមួយរួចមក អង្គការសមធម៌កម្ពុជាបានជួលមន្ត្រីទទួលបន្ទុកករណីថ្មីមួយរូប ដើម្បីឱ្យធ្វើការងារនៅកម្រិតមូលដ្ឋាន។

អង្គការសមធម៌កម្ពុជា បានដើរតួនាទីជាអន្តរការីមួយដ៏សំខាន់ ដើម្បីធានាថាសេចក្តីសម្រេចចិត្តឆាប់រហ័ស ដែលពាក់ព័ន្ធតួអង្គជាច្រើនយ៉ាងទូលំទូលាយ ត្រូវបានធ្វើឡើងនៅពេលដែលចាំបាច់ ព្រមទាំងផ្សព្វផ្សាយព័ត៌មាន និងផ្តល់បច្ចុប្បន្នភាពជាទៀងទាត់ ក្នុងអំឡុងពេលរង់ចាំដ៏វែង ដែលសកម្មភាពនេះមានសារៈសំខាន់ក្នុងការរក្សាឱ្យបាននូវសាមគ្គីភាព និងការប្តេជ្ញាចិត្តរបស់សហគមន៍ចំពោះដំណើរការនេះ។

⇒ **បើទោះបីជាវាមានសារៈសំខាន់ក្នុងការមានអង្គការនានាសហការនៅកម្រិតអន្តរជាតិ កម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ក៏ដោយ ប៉ុន្តែចំនួននៃអង្គការទាំងនេះគប្បីមានកម្រិត។ បន្ថែមពីនេះទៀត ត្រូវធានាឱ្យបាននូវការសម្របសម្រួលដ៏រឹងមាំនៅកម្រិតមូលដ្ឋាន តាមរយៈវត្តមានរបស់អង្គការជាតិនាំមុខ។**

## ការតាមដានស្វែងរកប្រភពថវិកា

យុទ្ធសាស្ត្រនេះធ្លាប់ត្រូវបានយកមកប្រើប្រាស់រួចទៅហើយ ប៉ុន្តែប្រសិទ្ធភាពរបស់វាបានបង្ហាញឱ្យឃើញយ៉ាងច្បាស់នៅក្នុងករណីនេះ។ វិនិយោគិនអាចមានលទ្ធភាពដាក់សម្ពាធជាពិសេសទៅលើក្រុមហ៊ុន ដើម្បីឱ្យដោះស្រាយការរំលោភសិទ្ធិមនុស្សរបស់ពួកគេ។ ពេលខ្លះ ក្រុមហ៊ុនបានវិលត្រឡប់ទៅការប្រកាន់យកជំហរមិនសហការវិញ ទាក់ទងនឹងការផ្តល់សំណង។ ក្រោយពេលដែលអ្នកផ្តល់កិច្ចគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ ត្រូវបានបញ្ចូលទៅក្នុងសកម្មភាពតស៊ូមតិ និងនៅពេលដែលការផ្តល់ហិរញ្ញវត្ថុគាំទ្រនៅពេលអនាគត ទទួលរងហានិភ័យដោយសារការតស៊ូមតិ ក្រុមហ៊ុនហុងអាញ់យាឡាយ កាន់តែមានឆន្ទៈក្នុងការសហការ និងដោះស្រាយបញ្ហាក្នុងលក្ខណៈមួយដែលសហគមន៍អាចទទួលយកបាន។

⇒ **ប្រសិនបើគ្មានសម្ពាធហិរញ្ញវត្ថុ និងការទាក់ទងដោយផ្ទាល់ជាមួយអ្នកផ្តល់កិច្ចគាំទ្រផ្នែកហិរញ្ញវត្ថុទេនោះ ដំណើរការដោះស្រាយវិវាទប្រាកដជានឹងគ្មានការវិវឌ្ឍន៍ទៅមុខឡើយ។**

## ការចរចារជាមួយអាជ្ញាធរថ្នាក់មូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិ

ភាពតានតឹងមួយចំនួនបានកើតឡើងជាមួយមន្ត្រីថ្នាក់ខេត្ត ឃុំ និងភូមិនៅពេលចាប់ផ្តើមដំណើរការដំបូង។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលកិច្ចគាំទ្រផ្លូវការទាំងនោះបានផ្តល់ភាពអនុគ្រោះទៅខាងភាគីក្រុមហ៊ុន ដោយមិនបានគិតគូរអំពីផលប្រយោជន៍របស់សហគមន៍ និងជាហេតុនាំឱ្យមានការមិនជឿទុកចិត្តដ៏យូរអង្វែង។ នៅពេលដែលមន្ត្រីថ្នាក់មូលដ្ឋានត្រូវបានបង្កលក្ខណៈឱ្យចូលរួមនៅក្នុងដំណើរការនេះ និងយល់ថាពុំមានការប្រឆាំងតវ៉ា ពេលនោះពួកគេបានផ្តល់កិច្ចសហការប្រសើរជាងមុន ចំពោះភូមិប្រមាណពាក់កណ្តាល នៃចំនួនភូមិសរុប។ សកម្មភាពនេះ អាចត្រូវបានធ្វើឡើងតាំងពីដំបូង ព្រមទាំងអាចសម្រួលដល់ការលំបាកមួយចំនួនផងដែរ ប៉ុន្តែរហូតដល់ពេលដែលការិយាល័យ CAO បានឈានដល់ការព្រមព្រៀងមួយជាមួយក្រសួងមហាផ្ទៃ ទើបអាជ្ញាធរ មូលដ្ឋានមានកាតព្វកិច្ចត្រូវអនុញ្ញាតឱ្យដំណើរការនេះបន្តប្រព្រឹត្តទៅដោយគ្មានការរំខាន។

⇒ **ការចរចារជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ខេត្ត មានសារៈសំខាន់ខ្លាំងណាស់នៅពេលចាប់ផ្តើមដំណើរការសម្រុះសម្រួលដោះស្រាយវិវាទ។ សម្រាប់ជំហានដំបូងនៃការគៀងគរភូមិរងផលប៉ះពាល់ ការប្រាស្រ័យទាក់ទងជាមួយមន្ត្រីថ្នាក់មូលដ្ឋាន អាចធ្វើឱ្យរីករាលដាលនូវភាពតានតឹង ឬមិនធ្វើឱ្យរីករាលដាលនូវភាពតានតឹង។**

# លក្ខខណ្ឌសម្រាប់ការចម្លងយកគំរូនេះ

- ក្រុមហ៊ុនត្រូវតែមានកម្រិតងាយរងគ្រោះគ្រប់គ្រាន់ចំពោះវិនិយោគិនរបស់ពួកគេ។
    - ចំពោះក្រុមហ៊ុនដែលមានរដ្ឋគាំទ្រពីក្រោយ ឬ មានទំនាក់ទំនងស៊ីជម្រៅជាមួយរដ្ឋាភិបាលជាតិរបស់ពួកគេ វាមានការលំបាកខ្លាំងជាងក្នុងការដាក់សម្ពាធទៅលើក្រុមហ៊ុនទាំងនោះ។
    - យ៉ាងហោចណាស់ ប្រសិនបើអាចរកឃើញចំណុចដាក់សម្ពាធមួយដ៏ខ្លាំង ទើបយុទ្ធសាស្ត្រនេះមានតម្លៃក្នុងការបន្តអនុវត្ត។ ប៉ុន្តែ បើទោះជាដូច្នេះក្តី ដើម្បីឱ្យមានប្រសិទ្ធភាពខ្លាំងបំផុតនោះ ត្រូវការឱ្យមានចំណុចដាក់សម្ពាធច្រើន។
    - យុទ្ធសាស្ត្រនេះមិនសូវមានប្រសិទ្ធភាពឡើយជាមួយវិនិយោគិនឯកជនតូចៗ។
- វិនិយោគិន និងម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ត្រូវមានឆន្ទៈក្នុងការគាំទ្រដល់យុទ្ធនាការតស៊ូមតិ និងដាក់សម្ពាធទៅលើក្រុមហ៊ុន។
- ចាំបាច់ត្រូវការឱ្យមានអង្គការដែលមានកម្រងនៃការប្រាស្រ័យទាក់ទង និងឥទ្ធិពលផ្សេងៗគ្នា។ អន្តរាគមន៍នេះ ទាមទារឱ្យមានអង្គការដែលមានជំនាញឯកទេសកម្រិតអន្តរជាតិ កម្រិតថ្នាក់ជាតិ និងកម្រិតមូលដ្ឋាន។
- អង្គការដែលផ្តួចផ្តើមដំណើរការនេះ ត្រូវមានមូលធនផ្នែកថវិកា និងមូលធនមនុស្សគ្រប់គ្រាន់ ដើម្បីចូលទៅក្នុងដំណើរការនេះ។
    - អង្គការសមធម៌កម្ពុជាតែឯងបានចំណាយថវិកាជាង ១០០.០០០ ដុល្លារសហរដ្ឋអាមេរិក ទៅហើយ ក្នុងរយៈពេល ២៧ខែនេះ ហើយនៅសល់ការងារជាច្រើនទៀតដែលត្រូវធ្វើ
    - ត្រូវធ្វើសិក្ខាសាលា និងការបណ្តុះបណ្តាលមួយចំនួនឱ្យបានល្អិតល្អន់ជាមួយសហគមន៍ និង ដៃគូនៅថ្នាក់មូលដ្ឋាន
        - អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន អាចត្រូវការការកសាងសមត្ថភាពយ៉ាងសំខាន់នៅគ្រប់ដំណាក់កាលទាំងអស់
    - ត្រូវការឱ្យមានជំនួយលើការពិនិត្យតាមដាន និងពេលវេលារបស់បុគ្គលិក នៅក្នុងចន្លោះពេលវេលាមួយដែលមិនទៀងទាត់។

    អង្គការត្រូវមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ភាពបត់បែនប្រភេទនេះ។

សហគមន៍ត្រូវធ្វើការវិនិយោគនៅក្នុងដំណើរការនេះ មានសាមគ្គីភាពរឹងមាំ និងទទួលបានឧបករណ៍ ដែលពួកគេត្រូវការដើម្បីបង្ហាញអំពីសេចក្តីត្រូវការរបស់ពួកគេឱ្យក្រុមហ៊ុនបានដឹង។ ប្រសិនបើគ្មានសហគមន៍ទេនោះ វាគឺជាបញ្ហារបស់អង្គការមិនមែនរដ្ឋាភិបាល និងពុំមានទម្ងន់អ្វីឡើយ។

⇒ ការវាយតម្លៃហានិភ័យផ្នែកសុវត្ថិភាពនៅក្នុងគ្រប់ស្ថានភាពទាំងអស់ ដើម្បីកំណត់ថាតើយុទ្ធសាស្ត្រនេះមានតម្លៃក្នុងការបន្តអនុវត្តនៅក្នុងករណីមួយដែរឬទេ។

# សេចក្តីសន្និដ្ឋាន

វិវាទដីធ្លីដែលបានរៀបរាប់នៅក្នុងឯកសារនេះ បង្ហាញអំពីហេតុការណ៍តូចមួយក្នុងសកលលោក ដែលការកែប្រែយ៉ាងឆាប់រហ័សនៃការប្រើប្រាស់ដីក្នុងទ្រង់ទ្រាយធំ ដោយទទួលបានមូលនិធិគាំទ្រពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនោះ កំពុងធ្វើឱ្យបាត់បង់ដីរបស់អ្នកកាន់កាប់ដីខ្នាតតូច និងជនជាតិដើមភាគតិច (Borras and Franco 2012)។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ការទន្ទ្រានយកដីបែបនេះ កើតឡើងនៅក្នុងបរិបទនៃរដ្ឋអន្តរកាល និងសម្ពាធដែលកំពុងកើនឡើង ដើម្បីធ្វើការ "អភិវឌ្ឍន៍" ឆ្ពោះទៅរកការប្រើប្រាស់ដីដែលមាន "ផលិតភាព" ខ្ពស់ (Harms and Baird 2014; Woods 2013)។ ក្រោយពេលទទួលបាន ជំនួយអភិវឌ្ឍន៍ និងបរិយាកាសដែល "បង្កលក្ខណៈងាយស្រួលចំពោះវិស័យឯកជន" អស់រយៈពេលជាង ម្ភៃឆ្នាំកន្លងមក (World Bank 2015, p.115) ប្រទេសកម្ពុជាបានកែប្រែប្រភេទប្រើប្រាស់ដីជាង ៤,៥ លានហិកតា ទៅឱ្យក្រុមហ៊ុនកសិកម្ម និងក្រុមហ៊ុនរុករករ៉ែ។ ផ្ទុយពីឯកសារផ្លូវការ ដីដែលត្រូវបានកែប្រែប្រភេទប្រើប្រាស់ទាំងនេះ ពុំមែនជាតំបន់ព្រៃរិចរិល ឬ ដីទំនេរឡើយ (Neef et al. 2013) ហើយវិវាទដីធ្លីរវាងក្រុមហ៊ុន និងសហគមន៍ដែលត្រូវបានជម្លៀសចេញ បាននិងកំពុងកើតឡើងដោយមិនអាចទប់ស្កាត់បានអស់រយៈពេល ១៥ឆ្នាំមកហើយ។

យន្តការដោះស្រាយវិវាទរបស់កម្ពុជា មានមូលដ្ឋានផ្អែកលើអន្តរាគមន៍របស់រដ្ឋាភិបាល និងច្បាប់ភូមិបាលជាតិ ដែលត្រូវបានរៀបចំឡើងដើម្បីឱ្យ ក្រុមហ៊ុនមានគណនេយ្យភាព ចំពោះសុច្ចរិតភាពផ្នែកសង្គម និងបរិស្ថានដែលជាហេតុនាំឱ្យមានស្ថានភាពមួយ "គ្មានយន្តការដោះស្រាយវិវាទ" (CCHR 2013, p.29)។ អ្វីដែលករណីសិក្សាខាងលើបានបង្ហាញ គឺមានយន្តការដទៃទៀតដែលស្ថិតនៅក្រៅបរិយាកាស ដ៏មានកម្រិតនៃគោលនយោបាយរបស់រដ្ឋ។ យន្តការផ្តល់មូលនិធិអន្តរជាតិ មានកាតព្វកិច្ចកាន់តែច្រើនឡើងជាលំដាប់ពីក្របខ័ណ្ឌបរិស្ថាន និងក្របខ័ណ្ឌសិទ្ធិមនុស្ស ហើយសហគ្រាសធុរកិច្ចខ្នាតធំ ក៏កំពុងតែសហការកាន់តែច្រើនឡើងជាលំដាប់ផងដែរជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។ ការស្វែងរក ព័ត៌មានអំពីទំនាក់ទំនងសហការផ្នែកហិរញ្ញវត្ថុទាំងនេះ ពុំមានភាពងាយស្រួលឡើយ (Dwyer 2015) ប៉ុន្តែ វាអាចធ្វើទៅបាន ដូចដែលករណីនេះបានបង្ហាញឱ្យឃើញស្រាប់។ លើសពីនេះទៀត វាបានផ្តល់ឱ្យ សហគមន៍នូវទម្រង់មួយនៃការទទួលបានប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ដែលពួកគេមិនអាចទទួលបាននៅក្នុង វិវាទដែលមានមូលដ្ឋានក្នុងប្រព័ន្ធបែបការិយាល័យធិបតេយ្យ និងប្រព័ន្ធច្បាប់របស់រដ្ឋ។ ការផ្សព្វផ្សាយជាសាធារណៈអំពីករណីបែបនេះ អាចបញ្ជូនសញ្ញាមួយដ៏ខ្លាំងក្លាទៅកាន់បណ្តាប្រទេសប្រភពដើមដែលផ្តល់ ការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) ព្រមទាំងបណ្តាក្រុមហ៊ុនអន្តរជាតិនានាដែលកំពុងពិចារណាធ្វើការវិនិយោគទៅលើវិស័យកសិកម្មក្នុងទ្រង់ទ្រាយធំ។

# ឯកសារយោង និងការផ្តល់មតិយោបល់អំពីឯកសារដែលគួរអាន


Borras, S. and Franco J. 2012. Global Land Grabbing and Trajectories of Agrarian Change: A Preliminary Analysis. *Journal of Agrarian Change* 12 (1): 34–59.

Bugalski, N. and Thuon, R. 2015. A Human Rights Impact Assessment: Hoang Anh Gia Lai Economic Land Concessions in Ratanakiri Province.” *In Land Grabbing, Conflict and Agrarian environmental Transformations: Perspectives from East and Southeast Asia*. Chiang Mai: BRICS Initiatives for Criti-cal Agrarian Studies (BICAS), MOSAIC Research Project, LDPI, RCSD Chiang Mai University, Transnational Institute.

Dwyer, M. 2015. *Trying to Follow the Money*. 177. Bogor Barat.

Global Witness. 2012. *Rubber Barons: How Vietnamese Companies and International Financiers Are Driving a Land Grabbing Crises in Cambodia and Laos*. London.

Harms, E. and Baird, I. G. 2014. Wastelands, Degraded Lands and Forests, and the Class (ification) Struggle: Three Critical Perspectives from Mainland Southeast Asia. *Singapore Journal of Tropical Geography* 35: 289–94.

Messerli, P., Peeters, A., Schoenweger, O., Nanhthavong, V., & Heinimann, A. (2015). Marginal Land or Marginal People? Analysing Patterns and Processes of Large-Scale Land Acquisitions in South-East Asia. In G. Christophe, C. Golay & P. Messerli (Eds.), *Large-Scale Land Acquisitions: Focus on South-East Asia* (Vol. International Development Policy series No.6, pp. 136-171). Geneva: Graduate Institute Publication.

Neef, A., Touch, Siphat. and Chiengthong, J.. 2013. The Politics and Ethics of Land Concessions in Rural Cambodia. Journal of Agricultural and Environmental Ethics 26: 1085–1103. doi:10.1007/s10806-013-9446-y.

Woods, K. 2013. *The Politics of the Emerging Agro-Industrial Complex in Asia's 'final Frontier': The War on Food Sovereignty in Burma*. Paper presented at the Conference 'Food Sovereignty: A Critical Dia- logue'. New Haven: Yale University.

World Bank. 2015. *Cambodian Agriculture in Transition: Opportunities and Risks*. Washington, D.C.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ ៖ ផែនទី

***ផែនទី ទី១ ៖ សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ និងភូមិដែលរងផលប៉ះពាល់ក្នុងខេត្តរតនៈគិរី***

តំបន់ដែលមានពណ៌ គឺជាដីសម្បទានរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ ដោយឡែកតំបន់ដែលមានពណ៌ប្រផេះ គឺជាតំបន់ដីសម្បទានដទៃទៀត និងតំបន់រាងការ៉េពណ៌ក្រហម គឺជាភូមិរងផលប៉ះពាល់។ មិនមែនគ្រប់ភូមិទាំងអស់ដែលរងផលប៉ះពាល់ ត្រូវបានកំណត់ថារងផលប៉ះពាល់ ដោយសារក្រុមហ៊ុនហុងអាញ់យាឡាយឡើយ។ ភូមិទាំង ១៤ នៅក្នុងករណីក្រុមហ៊ុនហុងអាញ់យាឡាយសុទ្ធសឹងតែបានធ្វើផែនទី ហើយផែនទីចំនួន២ក្នុងចំណោមផែនទីទាំងនោះ ត្រូវបានផលិតឡើងវិញដូចខាងក្រោម។ ភូមិកាក់ (ផែនទី ២) ត្រូវបានចង្អុលបង្ហាញតាមរយៈ*សញ្ញាមួយរាងរង្វង់មូល* និងភូមិកាំ (ផែនទី ៣) ត្រូវបានបង្ហាញតាមរយៈ សញ្ញាមួយរាងការ៉េ។ បើទោះបីជាភូមិទាំងនេះហាក់បីដូចជាមិនស្ថិតនៅក្នុងព្រំប្រទល់នៃដីសម្បទានក៏ដោយ ប៉ុន្តែផែនទីខាងក្រោម រៀបរាប់ឱ្យដឹងអំពីការទាមទារផ្ទៃដីដែលបានប្រើប្រាស់តាមបែបវិធានប្រពៃណី ដែលអាចលាតសន្ធឹងរាប់ពាន់ហិកតា។



### ផែនទី ទី២ ៖ ភូមិកាក់

នេះគឺជាផែនទីសហគមន៍មួយដែលរៀបរាប់លម្អិតអំពីធនធានរបស់សហគមន៍ និងការកាន់កាប់ដីធ្លី។ ខ្សែបន្ទាត់ដាច់ៗពណ៌ខៀវរត់កាត់ពាក់កណ្ដាលភូមិ គឺជាព្រំប្រទល់របស់ក្រុមហ៊ុន និងខ្សែបន្ទាត់ដាច់ៗពណ៌ខ្មៅ តំណាងឱ្យផ្ទៃដីដែលបានបាត់បង់ដោយសារតែការឈូសឆាយរបស់ក្រុមហ៊ុន។ បច្ចុប្បន្ន រូបភាពនៅក្នុងបរិវេណ នេះនោះបានបាត់បង់អស់ទៅហើយ។



### ផែនទី ទី៣ ៖ ភូមិកាំ

ផែនទីសហគមន៍នេះ ក៏បង្ហាញឱ្យដឹងផងដែរអំពីធនធាននៅក្នុងភូមិ ហើយខ្សែបន្ទាត់ដាច់ៗពណ៌ក្រហម បង្ហាញអំពីព្រំប្រទល់របស់ក្រុមហ៊ុន។ ក្រុមហ៊ុនមិនទាន់បានធ្វើការឈូសឆាយទៅលើផ្ទៃដីណាមួយនៅឡើយទេ ហើយការផ្តួចផ្តើមដែលមានពណ៌នានៅក្នុងរបាយការណ៍នេះ នឹងមិនធ្វើឱ្យភូមិនេះទទួលរងការខូចខាតឡើយ។



## ឧបសម្ព័ន្ធ២ ៖ ក្របខ័ណ្ឌពេលវេលា

***ពាក់កណ្ដាលឆ្នាំ២០១៣ ៖*** Global Witness បានទាក់ទងអង្គការ IDI ដោយអង្គការ IDI បានយល់ព្រមទទួលយកករណីនេះ ក្រោយពេលបានធ្វើការវិភាគបឋមទៅលើគោលនយោបាយរបស់ IFC និងពិនិត្យឡើងវិញទៅលើព័ត៌មានដែលបានដឹងរួចមកហើយ អំពីការពិតមួយចំនួននៅមូលដ្ឋាន។ នៅចុងឆ្នាំ ២០១៣ អង្គការ IDI បានបញ្ចូលអង្គការ សមធម៌កម្ពុជា ជាដៃគូក្នុងស្រុកសំខាន់របស់ខ្លួនសម្រាប់ករណីនេះ។

***ខែធ្នូ ឆ្នាំ២០១៣ ៖*** អង្គការ IDI និង អង្គការ សមធម៌កម្ពុជា បានរៀបចំធ្វើសិក្ខាសាលាមួយចំនួនក្នុង ខេត្តរតនៈគិរី ដើម្បីពន្យល់ជូនតំណាងសហគមន៍អំពីតួអង្គ ទំនាក់ទំនង និងយុទ្ធសាស្រ្តតស៊ូមតិដ៏ស្មុគស្មាញ ព្រមទាំងផ្ដល់ការបណ្ដុះបណ្ដាលអំពីសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ តំណាងសហគមន៍ បានបង្ហាញឱ្យឃើញពីបំណងចង់ឱ្យមានការដាក់ពាក្យបណ្ដឹងជំនួសឱ្យពួកគេ។ អង្គការ IDI និង អង្គការ សមធម៌កម្ពុជា បានទាក់ទងអង្គការជនជាតិដើមភាគតិចក្នុងមូលដ្ឋាន (HA, CIYA និង IRAM) ព្រមទាំងបានពន្យល់អំពីករណីនេះ និងបានលើកទឹកចិត្តឱ្យពួកគេចូលរួមជាអង្គការតំណាង អាស្រ័យដោយសហគមន៍រងផលប៉ះពាល់គឺជាជនជាតិដើមភាគតិច។ អង្គការជនជាតិដើមភាគតិចចំនួន៣ បានយល់ព្រមចូលរួមនៅក្នុងបណ្ដឹងនេះ។ អង្គការ IDI និង អង្គការ សមធម៌កម្ពុជា បានធ្វើការងារជាមួយអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ ដែលជាអង្គការមិនមែនរដ្ឋាភិបាលជាតិមួយ ដើម្បីផលិតជាខ្សែភាពយន្តមួយ ពន្យល់អំពីតួអង្គ និងយុទ្ធសាស្រ្តតស៊ូមតិ (ឧ. IFC, ការិយាល័យ CAO ។ល។) ខ្សែភាពយន្តនេះត្រូវបានបញ្ចូលសម្លេងជា ភាសាជនជាតិដើមភាគតិចចំនួន៤ផ្សេងៗគ្នា ព្រមទាំងបានចែកទៅឱ្យភូមិនីមួយៗ ដើម្បីជួយដល់តំណាងសហគមន៍ ក្នុងការផ្ទេរអ្វីដែលពួកគេបានរៀនសូត្រនៅក្នុងសិក្ខាសាលា ជូនដល់ប្រជាពលរដ្ឋនៅក្នុងភូមិរបស់ពួកគេ។

***ខែមករា ឆ្នាំ២០១៤ ៖*** អង្គការ IDI បានរៀបចំពាក្យបណ្ដឹងលម្អិតមួយ ដែលបញ្ជាក់អំពីភស្តុតាងនៃគ្រោះថ្នាក់នានា ការរំលោភបំពានគោលនយោបាយ និងការទាមទាររបស់សហគមន៍ សម្រាប់ដាក់ជូនទៅការិយាល័យភាពអនុលោម ទីប្រឹក្សាដោះស្រាយវិវាទ (CAO) នៃយន្តការគណនេយ្យភាព ឯករាជ្យរបស់ IFC។

***ខែកុម្ភៈ ឆ្នាំ២០១៤ ៖*** អង្គការ IDI និង អង្គការ សមធម៌កម្ពុជា បានធ្វើការរៀបចំត្រៀមលក្ខណៈតំណាងសហគមន៍ឱ្យជួបជាមួយ IFC ដើម្បីជូនដំណឹងដល់ IFC អំពីពាក្យបណ្ដឹងដែលពួកគេបម្រុង នឹងដាក់ជូន។ កិច្ចប្រជុំបានធ្វើឡើងនៅការិយាល័យរបស់ IFC ក្នុងរាជធានីភ្នំពេញ។ ពាក្យបណ្ដឹង ត្រូវបានដាក់ជូនទៅ IFC ហើយក្នុងថ្ងៃដដែលនេះ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍ បានធ្វើសន្និសីទសារព័ត៌មានមួយក្នុងរាជធានីភ្នំពេញ។ ការឆ្លើយតបភ្លាមៗ ពីក្រុមហ៊ុនហ៊ងអានយ៉ាឡាយ ដោយក្រុមហ៊ុននេះត្រូវបានជម្រុញឱ្យចូលរួមនៅក្នុងការសម្រុះសម្រួលដោះស្រាយវិវាទមួយដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ។ ពាក្យបណ្ដឹងនេះ ត្រូវបានការិយាល័យ CAO បញ្ជាក់ថាបានទទួល និងកំណត់ថាមានលក្ខខណ្ឌសមស្រប។

***ខែវិច្ឆិកា ឆ្នាំ២០១៣ - ខែមីនា ឆ្នាំ២០១៤ ៖*** អង្គការ IDI និង អង្គការ សមធម៌កម្ពុជា បានធ្វើការស្រាវជ្រាវដើម្បីប្រមូលភស្តុតាងអំពីផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងសកម្មភាពរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ ព្រមទាំងបានប្រើប្រាស់គំហើញបឋម ដើម្បីរៀបចំសេចក្តីព្រាងពាក្យបណ្តឹង ហើយក្រោយមកក៏បានផលិតនូវការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្សគ្រប់ជ្រុងជ្រោយមួយ។ ក្រុមស្រាវជ្រាវ បានធ្វើដំណើរចំនួន៤លើក ផ្សេងៗគ្នាទៅកាន់តំបន់នោះ និងធ្វើការប្រមូលទិន្នន័យពីភូមិទាំង១៨ ដែលអាចរងផលប៉ះពាល់ពីក្រុមហ៊ុនហុងអាញ់យាឡាយ។ ពួកគេបានគូរផែនទីភូមិលម្អិត ជាមួយសហគមន៍ចំនួន១៦ ព្រមទាំងបានធ្វើកិច្ចសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ចំនួន១៨ ក្រុមពិភាក្សាចំនួន១៨ កិច្ចពិភាក្សាក្រុមស្ត្រីចំនួន១៨ និងកិច្ចសម្ភាសន៍ តាមគ្រួសារចំនួន៨៧។ សកម្មភាពនេះគឺជាការវិនិយោគធនធានមនុស្សគួរឱ្យកត់សម្គាល់។

***ខែមេសា ឆ្នាំ២០១៤ ៖*** ការិយាល័យ CAO ធានាបាននូវការចូលរួមរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។

***ខែឧសភា - ខែធ្នូ ឆ្នាំ២០១៤***
***ខែសីហា និង ខែតុលា ឆ្នាំ២០១៤ ៖*** អង្គការ សមធម៌កម្ពុជា និងអង្គការ IDI បានផ្តល់ការបណ្តុះបណ្តាលអំពីជំនាញចរចារជូនសហគមន៍។

***ខែមករា - ខែកញ្ញា ឆ្នាំ២០១៥ ៖***
***ខែមករា ឆ្នាំ២០១៥ ៖*** តំណាងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលដែលជាទីប្រឹក្សា និងតំណាងក្រុមហ៊ុនហុងអាញ់យាឡាយ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ បានជួបជុំគ្នា ដើម្បីអនុម័តទៅលើ វិធានមូលដ្ឋានសម្រាប់គ្រប់គ្រងទៅលើដំណើរការដោះស្រាយវិវាទរបស់ការិយាល័យ CAO និង ដើម្បីឱ្យតំណាងសហគមន៍ អាចធ្វើការចែករំលែកអំពីរឿងរ៉ាវរបស់ពួកគេ ជាមួយក្រុមហ៊ុន ហុងអាញ់យាឡាយ។

***ខែកុម្ភៈ ឆ្នាំ២០១៥ ៖*** អង្គការ សមធម៌កម្ពុជា បានទទួលមូលនិធិឆាប់រហ័សរបស់ MRLG។ អង្គការ សមធម៌កម្ពុជា និងដៃគូអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន បានចូលរួមជាមួយក្រុមការងាររបស់ការិយាល័យ CAO នៅក្នុងដំណើរទស្សនកិច្ចទៅកាន់ភូមិនីមួយៗ ដើម្បីពន្យល់អំពីដំណើរការរបស់ការិយាល័យ CAO។ អង្គការមិនមែនរដ្ឋាភិបាល បានគាំទ្រដល់តំណាងសហគមន៍ដែលមកពីភូមិនីមួយៗ ក្នុងការប្រមូលព័ត៌មានលម្អិតអំពីការខាតបង់ និងផលប៉ះពាល់ ព្រមទាំងបញ្ហាដែលពួកគេចង់ឱ្យដោះស្រាយ។

***ខែមីនា ឆ្នាំ២០១៥ ៖*** សិក្ខាសាលារំលឹកឡើងវិញអំពីជំនាញចរចារ និងការតស៊ូមតិ សម្រាប់តំណាងសហគមន៍មុនពេលកិច្ចប្រជុំរបស់ការិយាល័យ CAO។

កិច្ចប្រជុំសម្រុះសម្រួលដោះស្រាយវិវាទរបស់ការិយាល័យ CAO ជាមួយអ្នកតំណាងក្រុមហ៊ុនហុងអាញ់យាឡាយ អង្គការ សមធម៌កម្ពុជា អង្គការដៃគូ និងតំណាងសហគមន៍ មកពីភូមិ រងផលប៉ះពាល់ទាំង១៧។

តំណាងសហគមន៍ បានបង្ហាញអំពី "ការទាមទារជាសមូហភាព" ទាំង១៤ចំណុច ទៅកាន់ក្រុមហ៊ុនហុងអាញ់យាឡាយ ដោយបញ្ជាក់ថាតើការផ្តល់សំណងប្រកបដោយអត្ថន័យ មានន័យ ដូចម្តេចចំពោះពួកគេក្នុងលក្ខណៈជាក្រុម។ ក្រុមហ៊ុនហុងអាញ់យាឡាយ បានប្តេជ្ញាបន្តផ្អាកការឈូសឆាយរបស់ខ្លួនរហូតដល់ពេលដែលបញ្ហាជាមួយសហគមន៍ត្រូវបានដោះស្រាយរួចរាល់។

***ខែមេសា ឆ្នាំ២០១៥ ៖*** អង្គការ សមធម៌កម្ពុជា បានរកឃើញថាក្រុមហ៊ុនហុងអាញ់យាឡាយ បានចូលរួមនៅក្នុងសកម្មភាពមួយចំនួន ដែលស្ថិតនៅក្រៅដំណើរការសម្រុះសម្រួលដោះស្រាយវិវាទ ហើយត្រូវបានបង្ខំឱ្យចេញលិខិតហាមប្រាមចំពោះការប្រាស្រ័យទាក់ទង ទៅក្រុមហ៊ុនហុងអាញ់យាឡាយ។

ការបញ្ជាក់លម្អិតអំពីព័ត៌មាន រវាងការិយាល័យ CAO និង បណ្តាភូមិនានា មានការសម្របសម្រួលពី អង្គការសមធម៌កម្ពុជា។

ការប្រាស្រ័យទាក់ទង និង ការពិភាក្សាជាមួយអ្នកផ្តល់ហិរញ្ញប្បទានគាំទ្រ និង ម្ចាស់ភាគហ៊ុនរបស់ ក្រុមហ៊ុនហុងអាញ់យាឡាយ។

***ខែឧសភា ឆ្នាំ២០១៥ ៖*** បន្តការងាររៀបចំទិន្នន័យដែលត្រូវការ សម្រាប់ការសម្រុះសម្រួលដោះស្រាយវិវាទ និងសម្របសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានរវាងការិយាល័យ CAO និង បណ្តាភូមិនានា។

***ខែមិថុនា ឆ្នាំ២០១៥ ៖*** ការទាមទាររបស់ភូមិនីមួយៗ ដែលរាប់បញ្ចូលទាំងបញ្ជីសារពើភ័ណ្ឌអំពីការខាតបង់ និងផលប៉ះពាល់ ព្រមទាំងការទាមទារចំពោះការខាតបង់ និងផលប៉ះពាល់ទាំងនោះ ដែលបានចងក្រងដោយតំណាងសហគមន៍ ត្រូវបានផ្តល់ជូនទៅឱ្យក្រុមហ៊ុនហុងអាញ់យាឡាយ។

***ខែកក្កដា ឆ្នាំ២០១៥ ៖*** សិក្ខាសាលាសហគមន៍ស្តីពី "ជម្រើសនានាសម្រាប់កិច្ចព្រមព្រៀងដែលអាចធ្វើទៅបាន"។ ក្រុមហ៊ុនហុងអាញ់យាឡាយ បានឆ្លើយតបទៅនឹងការទាមទាររបស់សហគមន៍ ដោយនិយាយថាពួកគេនឹងមិនប្រគល់មកវិញនូវដីណាមួយឡើយ ដែលចំណុចនេះគឺជាការទាមទារចម្បងរបស់សហគមន៍។ អង្គការ IDI និងអង្គការសមធម៌កម្ពុជា បានលុបចោលនូវការសម្រុះសម្រួលដោះស្រាយវិវាទក្នុងខែសីហា ជាមួយក្រុមហ៊ុនហុងអាញ់យាឡាយ ដោយសារតែការចរចារដោយ ទុច្ចរិតនេះ ហើយបានចូលរួមនៅក្នុងការតស៊ូមតិពីវិនិយោគិនវិញ។

***ខែសីហា ឆ្នាំ២០១៥ ៖*** ការផ្តល់ជំនួយជូនដល់សហគមន៍ដើម្បីគូសគំនូសព្រាងផែនទីបែបប្រពៃណី ដែលបង្ហាញអំពីព្រំប្រទល់ភូមិរបស់ពួកគេ ការប្រើប្រាស់ដី និងលក្ខណៈពិសេសពីធម្មជាតិ ព្រមទាំងតំបន់ទាំងឡាយណា ដែលរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។

***ខែកញ្ញា ឆ្នាំ២០១៥ ៖*** កិច្ចប្រជុំរួម ដែលនៅក្នុងកិច្ចប្រជុំនេះ ក្រុមហ៊ុនហុងអាញ់យាឡាយ បានផ្តល់ការប្តេជ្ញាចិត្តចំពោះសហគមន៍ទាំង១៤ ដែលបានបញ្ជាក់ថារងផលប៉ះពាល់ដោយសារក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ ក្នុងខេត្តរតនៈគិរី។

***ខែវិច្ឆិកា ឆ្នាំ២០១៥ - ខែមីនា ឆ្នាំ២០១៦***

***ខែមីនា ឆ្នាំ២០១៦ ៖*** កិច្ចប្រជុំរវាងការិយាល័យ CAO និង អ្នកតំណាងក្រុមហ៊ុនហុងអាញ់យាឡាយក្នុងប្រទេសវៀតណាម។

កិច្ចប្រជុំរវាងអង្គការ សមធម៌កម្ពុជា អង្គការតំណាងថ្នាក់មូលដ្ឋាន និងការិយាល័យ CAO ក្នុងខេត្តរតនៈគិរី។

វគ្គបណ្តុះបណ្តាលជាមួយអង្គការ សមធម៌កម្ពុជា អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងតំណាងសហគមន៍ ដើម្បីពិភាក្សាអំពីការវិវឌ្ឍថ្មីៗ និងផ្តល់ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ឧបករណ៍ GPS សម្រាប់សកម្មភាពបន្តធ្វើការកំណត់ផែនទីព្រំប្រទល់។

***គម្រោងអភិបាលកិច្ចដីធ្លីតំបន់មេគង្គ*** *មានគោលបំណងរួមចំណែកដល់ការរៀបចំឱ្យមានគោលនយោបាយដីធ្លី និងការអនុវត្តសមស្របនៅក្នុងតំបន់មេគង្គ សំដៅឆ្លើយតបទៅនឹងអាទិភាពជាតិ ចំពោះការកាត់បន្ថយភាពក្រីក្រ ការកែលម្អអាហារូបត្ថម្ភ ការបង្កើនការអភិវឌ្ឍសេដ្ឋកិច្ច និង ការគាំទ្រដល់ គ្រួសារកសិករ ដើម្បីឱ្យពួកគេអាចមានសុវត្ថិភាពដីធ្លី និងធ្វើសេចក្ដីសម្រេចចិត្តបានល្អអំពីការប្រើប្រាស់ និងការគ្រប់គ្រងដី។ MRLG កំពុងមានប្រតិបត្តិការក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម តាំងពី ខែមេសា ឆ្នាំ២០១៤ ដោយទទួលបានកិច្ចគាំទ្រពី SDC និងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់។ សម្រាប់ព័ត៌មានបន្ថែមអំពី MRLG សូមមើល www.mrlg.org ។*

***កម្រងនៃឯកសារសម្រាប់ការរៀនសូត្ររបស់ MRLG*** *គូសបញ្ជាក់អំពីមេរៀនសំខាន់ៗ ដែលទទួលបានពីសកម្មភាព និងការចូលរួមរបស់បុគ្គល ក្រុម និង ស្ថាប័នមួយចំនួន ដែលមានបំណងស្វែងយល់ឱ្យបានកាន់តែប្រសើរឡើង និងធ្វើការដោះស្រាយបញ្ហាអសុវត្ថិភាពដីធ្លីរបស់កសិករខ្នាតតូចនៅក្នុងតំបន់មេគង្គ។ ឯកសារនេះមានគោលបំណងរួមចំណែកដល់ដំណើរការរៀនសូត្ររបស់អង្គការដៃគូ និងចែករំលែកនូវមេរៀននានា ជាមួយភាគីដទៃទៀតដែលមានចំណាប់អារម្មណ៍។ ដូច្នេះ ឯកសារនេះរួមមានសេចក្ដីពណ៌នាច្បាស់លាស់មួយអំពីបញ្ហា និងសកម្មភាពនានា ព្រមទាំងការវិភាគស៊ីជម្រៅទៅលើលទ្ធផល និងឥទ្ធិពលដែលសម្រេចបាន។ ការផលិតឯកសារសម្រាប់ការរៀនសូត្រនេះ បានទទួលការសម្របសម្រួលពីគណៈកម្មាធិការដឹកនាំពិនិត្យកែសម្រួលមួយដែលមានសមាសភាពចូលរួមពីតំណាងរបស់ MRLG អង្គការដៃគូ និងជំនាញការដែលត្រូវបានអញ្ជើញឱ្យចូលរួម។*

***អង្គការ សមធម៌កម្ពុជា*** *គឺជាអង្គការមិនមែនរដ្ឋាភិបាលជាតិមួយ ដែលធ្វើការងារដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយសមធម៌ និងការសម្រេចបានជាលំដាប់នូវសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា តាមរយៈការស្រាវជ្រាវ ការតស៊ូមតិដែលមានមូលដ្ឋានផ្អែកលើភស្តុតាង និងការចងក្រងសហគមន៍។ សម្រាប់ព័ត៌មានបន្ថែមអំពីអង្គការសមធម៌កម្ពុជា សូមមើល www.equitablecambodia.org ។*

***អង្គការ Inclusive Development International*** *គឺជាអង្គការសិទ្ធិមនុស្សមួយ ដែលគាំទ្រដល់សហគមន៍ ក្នុងការការពារដីធ្លី និងសិទ្ធិមនុស្សរបស់ពួកគេ ក្នុងករណីដែលមានការអភិវឌ្ឍ និងគម្រោងវិនិយោគដែល បង្កគ្រោះថ្នាក់ដល់ពួកគេ និងធ្វើការងារដើម្បីពង្រឹងទៅលើលិខិតបទដ្ឋានគតិយុត្តិ និងគណនេយ្យភាពរបស់សារជីវកម្ម និងស្ថាប័នហិរញ្ញវត្ថុនានា។ សម្រាប់ព័ត៌មានបន្ថែមអំពី IDI សូមមើល www.inclusivedevelopment.net ។*

*ទស្សនៈ យោបល់ និង ការបកស្រាយនៅក្នុងឯកសារនេះ គឺជាទស្សនៈ យោបល់ និង ការបកស្រាយរបស់អ្នកនិពន្ធ និងអ្នកផ្ដល់វិភាគទាន។ ទស្សនៈ យោបល់ និង ការបកស្រាយទាំងនេះ មិនគួរត្រូវបានយកមកបកស្រាយថាតំណាងឱ្យទស្សនៈ ឬ ជំហរជាផ្លូវការ ឬ មិនផ្លូវការរបស់ SDC ឬ BMZ ឡើយ។*

**ផ្ដល់មូលនិធិដោយ**

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra
Swiss Agency for Development and Cooperation SDC

german cooperation
DEUTSCHE ZUSAMMENARBEIT

**អនុវត្តដោយ**

LAND equity

GRET
Professionals for Fair Development

**គាំទ្រដោយ**

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH